អង្គការសមាគមធាងត្នោត

Sahmakum Teang Tnaut Organization · a Cambodian Urban NGO

# ការគ្រប់គ្រងសំរាម សំណល់រឹង រាជធានីភ្នំពេញ ២០២៤

## ការប្រៀបធៀបរវាងទីតាំងលំនៅឋានក្រីក្រ និងទីតាំងលំនៅឋានទូទៅ



# សេចក្តីសង្ខេប



*រូបភាពទី១៖ គំនរសំរាមនៅទីតាំងលំនៅឋានក្រីក្រដែលបានផ្តល់បទសម្ភាស*

ការស្រាវជ្រាវនេះ ផ្តោតលើបញ្ហាប្រឈមសំខាន់ៗនៃការគ្រប់គ្រងសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ ដោយផ្តោតលើភាពខុសគ្នារវាងទីតាំងលំនៅឋានក្រីក្រ និងទីតាំងលំនៅឋានទូទៅ។ ការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងទីក្រុងមិនគ្រាន់តែជាបញ្ហាអនាម័យប៉ុណ្ណោះទេ ប៉ុន្តែប៉ះពាល់ដល់សុខភាពសាធារណៈ គុណភាពជីវិត និងការអភិវឌ្ឍប្រកបដោយចីរភាពនៃទីក្រុង។ ការសិក្សាឈ្វេងយល់ដើម្បីកំណត់បញ្ហាជាក់លាក់ និងស្នើអនុសាសន៍ដែលអាចអនុវត្តបានដល់ភាគីពាក់ព័ន្ធជាពិសេសអាជ្ញាធរមូលដ្ឋាន ក្រុមហ៊ុនប្រមូលសំរាម ទីតាំងលំនៅឋានទូទៅ និងទីតាំងលំនៅឋានក្រីក្រ ដើម្បីបង្កើនប្រសិទ្ធភាពដល់ប្រព័ន្ធគ្រប់គ្រងកាកសំណល់។

ផ្អែកលើ ការស្ទង់មតិជាមួយប្រជាពលរដ្ឋប្រមាណចំនួន ២០៣គ្រួសារ ដែលនៅក្នុងមានចំនួន ១៤ទីតាំងលំនៅឋានក្រីក្រ និងចំនួន១៤ភូមិដែលជាទីតាំងលំនៅឋានទូទៅ។ លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញពីកង្វះប្រសិទ្ធភាពនៅក្នុងផ្នែកប្រតិបត្តិការសំខាន់ៗនៃការប្រមូលសំរាម កង្វះការយល់ដឹងជាសាធារណៈលើការគ្រប់គ្រងសំរាម សំណល់រឹង និងបញ្ហាប្រឈមផ្នែកអភិបាលកិច្ចនៅក្នុងការគ្រប់គ្រងសំរាម សំណល់រឹង។ ការសិក្សានេះ មានគោលបំណងលើកកម្ពស់ការគ្រប់គ្រងសំរាម សំណល់រឹងឱ្យមានប្រសិទ្ធភាព និងសមធម៌នៅក្នុងទីក្រុង និងផ្តល់នូវផែនទីបង្ហាញផ្លូវច្បាស់លាស់សម្រាប់អ្នកធ្វើគោលនយោបាយ និងអ្នកពាក់ព័ន្ធនានា ដើម្បីដោះស្រាយបញ្ហាដែលកំពុងប្រឈម។

១. ប្រជាពលរដ្ឋ កំពុងប្រឈមនឹងកង្វះកន្លែងទុកដាក់ ឬចោលសំរាមមានចំនួន ២៦%។ ការកង្វះទីតាំងចោលសំរាមបែបនេះអាចបណ្តាលឱ្យមានការចោលសំរាមមិនរៀបរយនៅតាមទីសាធារណៈ ដែលនឹងបង្កឱ្យមានបញ្ហាដល់ផ្នែកសុខភាព និងការប៉ះពាល់ដល់បរិស្ថាន។ អន្តរាគមន៍ភ្លាមៗគួរតែផ្តោតលើការបង្កើតកន្លែងចោលសំរាមនៅខាងក្នុង ឬក្បែរទីតាំងលំនៅឋានក្រីក្រ និងប្រើប្រាស់រថយន្តប្រមូលសំរាមខ្នាតតូចសម្រាប់ផ្លូវតូចចង្អៀត។

២. ការយល់ដឹងជាសាធារណៈ និងការអនុលោមតាមការបែងចែកសំរាម សំណល់រឹងនៅតែមានកម្រិតទាបនៅឡើយ ពីព្រោះមានតែអ្នកផ្តល់បទសម្ភាស ៣១% ប៉ុណ្ណោះ ដែលបានញែកសំរាម សំណល់រឹង តាមប្រភេទសើម និងស្ងួតជាទៀងទាត់។ ដើម្បីដោះស្រាយបញ្ហានេះ យុទ្ធនាការអប់រំជាសាធារណៈគួរផ្តល់អាទិភាព ដែលសង្កត់ធ្ងន់លើសារៈសំខាន់ និងអត្ថប្រយោជន៍នៃការញែកសំរាម សំណល់រឹង។ លើសពីនេះ ក្រុមហ៊ុនគ្រប់គ្រងសំរាមត្រូវតែធានាឱ្យមានការញែក និងការអនុវត្តការប្រមូលឱ្យបានត្រឹមត្រូវ ដើម្បីកសាងទំនុកចិត្ត និងលើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណជន។

៣. ការសិក្សាក៏បានរកឃើញភាពមិនស៊ីសង្វាក់គ្នានៃការផ្តល់សេវាកម្មប្រមូលសំរាមផងដែរ ដោយ ជាង៧០% នៃអ្នកផ្តល់បទសម្ភាសបានលើកឡើងពីភាពមិនទៀងទាត់រវាងការបញ្ចេញសំរាម និងប្រមូលសំរាមដែលត្រូវតាមកាលវិភាគប្រមូលសំរាមនោះទេ។ ករណីនេះបានរកឃើញមូលហេតុចម្បងៗ ដោយសារតែផ្លូវតូចមិនអាចឱ្យឡានដឹកសំរាមចូលមកប្រមូលសំរាមបាន និងពេលវេលាប្រមូលសំរាមមិនច្បាស់លាស់ ឬទៀងទាត់។ ការពង្រឹងកិច្ចសហការរវាងក្រុមហ៊ុនគ្រប់គ្រងសំរាម និងអាជ្ញាធរមូលដ្ឋានមានសារៈសំខាន់ណាស់ក្នុងការបង្កើតកាលវិភាគប្រមូលសំរាមដែលមានភាពទៀងទាត់ តម្លាភាព និងអាចទុកចិត្តបាន។ ការចូលរួមរបស់ទីតាំងលំនៅឋានក្រីក្រអាចជំរុញឱ្យកម្មវិធីទូរស័ព្ទ ឬមជ្ឈមណ្ឌលប្រមូលសំរាមក្នុងមូលដ្ឋានទទួលបានផ្តល់ព័ត៌មានទាន់ពេលវេលា ជាក់ស្តែង និងមតិយោបល់កែលម្អលើការផ្តល់សេវាកម្មប្រមូលសំរាម។

លើសពីនេះ ការចូលរួមជាសាធារណៈក្នុងកម្មវិធីគ្រប់គ្រងសំរាម សំណល់រឹងមានកម្រិតទាបដោយមានអ្នកផ្តល់បទសម្ភាសមានត្រឹមតែ ៣៣% ប៉ុណ្ណោះ ដែលបានដឹងពីកាលវិភាគប្រមូលសំរាមនៅក្នុងតំបន់របស់ពួកគេ។ ជាងនេះ ព័ត៌មានអំពីបណ្តាញ ឬស្ថាប័នសំខាន់ៗនានា ក៏បានផ្តាច់ទំនាក់ទំនងរវាងអ្នកផ្តល់សេវាកម្ម និងអ្នកប្រើប្រាស់សេវាកម្ម ដែលជាឧបសគ្គរាំងដល់ប្រជាពលរដ្ឋមិនអាចរាយការណ៍នូវបញ្ហាប្រឈមអំពីការគ្រប់គ្រងសំរាម សំណល់រឹងបាន។ ហេតុនេះ ការបង្កើតគំរូអភិបាលកិច្ចដែលមានការចូលរួម ដូចជាវេទិកាពិគ្រោះយោបល់ជាទៀងទាត់ អាចផ្តល់សិទ្ធិអំណាចដល់អ្នកប្រើប្រាស់សេវាក្នុងការបង្ហាញពីកង្វល់ និងសហការ ដើម្បីកែលម្អយុទ្ធសាស្ត្រគ្រប់គ្រងសំរាម សំណល់រឹងឱ្យកាន់តែមានប្រសិទ្ធភាព។

ចំណែកក្របខ័ណ្ឌច្បាប់ និងគោលនយោបាយរួមទាំងអនុក្រឹត្យឆ្នាំ១៩៩៩ របស់ប្រទេសកម្ពុជា ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹ និងគោលនយោបាយគ្រប់គ្រងសំណល់រឹងទីក្រុងឆ្នាំ ២០២០-២០៣០ បានផ្តល់គោលការណ៍ណែនាំច្បាស់លាស់សម្រាប់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តនៅតែមិនស្មើគ្នា ជាពិសេសនៅក្នុងតំបន់ដែលជាទីតាំងលំនៅឋានក្រីក្រដែលមានការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ និងធនធាន។ ដូច្នេះ យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងថ្នាក់ជាតិត្រូវតែពិនិត្យមើលលើតម្រូវការទីតាំងលំនៅឋានក្រីក្រជាអាទិភាព។ ជា

ដំណោះស្រាយការរៀបចំរចនាសម្ព័ន្ធអភិបាលកិច្ចទីក្រុង នៅក្នុងមូលដ្ឋានីយកម្ម ត្រូវតែជានាឱ្យបាននូវគោលនយោបាយដែលមានការកែសម្រួលដើម្បីដោះស្រាយបញ្ហាប្រឈមជូនទីតាំងលំនៅឋានទូទៅ និងទីតាំងលំនៅឋានក្រីក្រ។

អនុសាសន៍សំខាន់ៗ ដើម្បីកែលម្អការគ្រប់គ្រងសំរាម សំណល់រឹង រួមមានការសាងសងហេដ្ឋារចនាសម្ព័ន្ធបន្ទាន់ ជាពិសេសនៅក្នុងតំបន់ដែលមានផ្លូវតូចចង្អៀត និងមិនទាន់មានកន្លែងទុកដាក់សំរាម ឬចោលសំរាម ដើម្បីពង្រីកសមត្ថភាពប្រមូលសំរាម។ គួរមានគំនិតផ្តួចផ្តើម ឬគម្រោងដែលជំរុញឱ្យមានការចូលរួមពីទីតាំងលំនៅឋានក្រីក្រ ដូចជាផ្តល់ជូនរង្វាន់សម្រាប់អ្នកដែលបានអនុវត្តការញែកសំរាម សំណល់រឹងបានត្រឹមត្រូវ ដែលកត្តានេះ អាចបង្កើនការចូលរួមពីប្រជាពលរដ្ឋបានមួយកម្រិតទៀតផងដែរ។ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលផ្តល់ជូននូវការធ្វើបច្ចុប្បន្នភាពពេលវេលាជាក់ស្តែងលើកាលវិភាគប្រមូលសំរាម និងការតាមដាន GPS នៃរថយន្តប្រមូលសំរាមអាចបង្កើនគណនេយ្យភាព និងប្រសិទ្ធភាពនៃការប្រមូលសំរាមផងដែរ។ ការគ្រប់គ្រងសំរាមដែលទទួលបានប្រសិទ្ធភាព មានការសម្របសម្រួលល្អ និងឆ្លើយតបទាន់ពេលវេលានោះ គឺគួរតែមានការពង្រឹងភាពជាដៃគូរវាងសាធារណៈ និងឯកជន ការបណ្តុះបណ្តាលអ្នកដឹកនាំក្នុងមូលដ្ឋាន ដើម្បីសម្របសម្រួល និងការដោះស្រាយបញ្ហានានា របស់ប្រជាពលរដ្ឋ។

ជារួម ការសិក្សានេះបង្ហាញពីតម្រូវការបន្ទាន់ដែលមានលក្ខណៈបរិយាបន្ន និងឆ្លើយតបពីប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងរាជធានីភ្នំពេញ ដែលជាការតភ្ជាប់ ឬទំនាក់ទំនងរវាងគោលនយោបាយក្របខណ្ឌជាតិ អន្តរជាតិ និងការរស់នៅរបស់ប្រជាពលរដ្ឋ។ តាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធឱ្យល្អប្រសើរនៅតាមតំបន់គោលដៅ ត្រូវតែលើកកម្ពស់ការចូលរួមពីសាធារណជន និងការទទួលយកបច្ចេកវិទ្យាច្នៃប្រឌិត។ រាជធានីភ្នំពេញអាចដោះស្រាយបញ្ហាប្រឈមសំខាន់ៗនៃការគ្រប់គ្រងសំរាម សំណល់រឹងប្រកបដោយប្រសិទ្ធភាព។ ទីក្រុងស្អាត សុខភាពល្អ និងនិរន្តរភាព អាចសម្រេចបានត្រូវមានការសម្របសម្រួល និងការបន្តចូលរួមរបស់ទីតាំងលំនៅឋានក្រីក្រ រាជរដ្ឋាភិបាល និងសេវាកម្មគ្រប់គ្រងសំរាម សំណល់រឹងឯកជន។ ការសិក្សាស្រាវជ្រាវនេះ ស្វែងរកអន្តរាគមន៍ភ្លាមៗដែលផ្តល់អាទិភាពដល់ទីតាំងលំនៅឋានក្រីក្រដែលងាយរងគ្រោះ និងពង្រឹងរចនាសម្ព័ន្ធអភិបាលកិច្ច ដើម្បីជានាការគ្រប់គ្រងសំរាមសំណល់រឹងប្រកបដោយសមធម៌ និងនិរន្តរភាពសម្រាប់ទាំងអស់គ្នានៅក្នុងរាជធានីភ្នំពេញ។

# មាតិកា


១. សេចក្តីផ្តើម ........ ១
២. ទិដ្ឋភាពនៃច្បាប់ជាតិ គោលនយោបាយ និងបទប្បញ្ញត្តិ ........ ២
២.១) ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ........ ២
២.២) គោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជន ឆ្នាំ២០២០ ដល់២០៣០ ........ ២
២.៣) បទប្បញ្ញត្តិនានា ........ ៣
៣. ទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌអន្តរជាតិទាក់ទងនឹងការគ្រប់គ្រងសំរាម សំណល់រឹង ........ ៤
៣.១) អនុសញ្ញា Basel ស្តីពីការគ្រប់គ្រងចលនាឆ្លងដែននៃសំរាម សំណល់រឹងគ្រោះថ្នាក់ និងការបោលរបស់ពួកគេ (១៩) ........ ៤
៣.២) កិច្ចព្រមព្រៀងទីក្រុងប៉ារីស (២០១៥) ........ ៥
៣.៣) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) (២០១៥) ........ ៥
៣.៤) កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) គោលការណ៍ណែនាំអំពីការគ្រប់គ្រងសំរាម សំណល់រឹង ........ ៦
៤. វិធីសាស្ត្រស្រាវជ្រាវ ........ ៨
៤.១) គោលបំណងស្រាវជ្រាវ ........ ៨
៤.២) វិធីសាស្ត្រប្រមូលទិន្នន័យ ........ ៨
៤.៣)ទំហំសំណាកដែលបានជ្រើសរើស ........ ៨
៤.៤) ការវិភាគទិន្នន័យ ........ ១១
៤.៥) វិសាលភាពសម្រាប់ការស្រាវជ្រាវ ........ ១១
៤.៦) ព័ត៌មានប្រជាសាស្ត្រ ........ ១១
៥. លទ្ធផលស្រាវជ្រាវសំខាន់ៗ ........ ១៤
៥.១) ទីតាំងបោលសំរាម សំណល់រឹង ........ ១៤
៥.២) ការទុកដាក់សំរាម សំណល់រឹង ........ ១៥
៥.៣) ការញែកសំរាម សំណល់រឹង ........ ១៧
៥.៤) ម៉ោងបញ្ចេញសំរាម សំណល់រឹង ឬបោលសំរាម សំណល់រឹង ........ ១៨
៥.៥) ចំណេះដឹងរបស់អ្នកផ្តល់បទសម្ភាសទាក់ទងនឹងច្បាប់ និងបទប្បញ្ញត្តិនានា ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ ........ ២០
៥.៦) វិភាគការចូលរួមក្នុងកិច្ចការគ្រប់គ្រងសំរាម សំណល់រឹងរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងការឆ្លើយតបរបស់អជ្ញាធរមូលដ្ឋាន ........ ២០
ករណីសិក្សាទី១៖ ការគ្រប់គ្រងសំរាម សំណល់រឹងក្នុងសហាហគមន៍ក្រីក្រ ........ ២២
ក. ការចំណាយថវិកាលើសពីថ្លៃសេវា ........ ២២

ខ. បញ្ហាសំរាម សំណល់រឹងឈានដល់ការប្រើហិង្សារវាងគ្នានឹងគ្នា ....................................២៤
គ. ការយល់ច្រលំថាទីតាំងលំនៅឋានក្រីក្រមិនតម្រូវឱ្យមានការបង់ថ្លៃសេវាប្រមូលសំរាម សំណល់រឹង ....................................២៥
ករណីសិក្សាទី២៖ ការគ្រប់គ្រងសំរាម សំណល់រឹងរបស់ទីតាំងលំនៅឋានទូទៅ ....................................២៧
ប្រៀបធៀបករណីសិក្សាលើការប្រើប្រាស់សេវាកម្មប្រមូលសំរាម សំណល់រឹងរវាងទីតាំងលំនៅឋានក្រីក្រ និងទីតាំងលំនៅឋានទូទៅ....................................២៨
៦. បញ្ហាប្រឈមក្នុងការគ្រប់គ្រងសំរាម សំណល់រឹងក្នុងតំបន់គោលដៅដែលបានផ្តល់បទសម្ភាស .....២៩
៦.១) បញ្ហាប្រឈមចម្បងៗដោយកង្វះការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន....................................២៩
៦.២) បញ្ហាប្រឈមចម្បងៗដោយសារការចូលរួមមិនបានពេញលេញរបស់ក្រុមហ៊ុនប្រមូលសំរាម សំណល់រឹង....................................២៩
៧. សេចក្តីសន្និដ្ឋាន....................................៣១
៨. អនុសាសន៍ ....................................៣២

# ១. សេចក្តីផ្តើម

ការគ្រប់គ្រងសំរាម សំណល់រឹងប្រកបដោយប្រសិទ្ធភាពគឺជាបញ្ហាសំខាន់នៅក្នុងតំបន់ទីក្រុង ដែលប៉ះពាល់ដល់ទាំងនិរន្តរភាពបរិស្ថាន និងសុខភាពសាធារណៈ។ នៅរាជធានីភ្នំពេញ បញ្ហាប្រឈមនៃការចោលសំរាម សំណល់រឹង ដោយអនុវត្តការទុកដាក់សំរាមមិនត្រឹមត្រូវ គ្មានការញែកសំរាម ពេលវេលាបញ្ចេញចោលមិនត្រឹមត្រូវ និងការប្រមូលមិនទៀងទាត់ ដែលអាចប៉ះពាល់ធ្ងន់ធ្ងរដល់ប្រជាពលរដ្ឋ ជាពិសេសទីតាំងលំនៅឋានក្រីក្រ។ ការសិក្សានេះពិនិត្យមើលលើស្ថានភាពបច្ចុប្បន្ននៃការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹង ក្នុងចំណោមអ្នកផ្តល់បទសម្ភាសចំនួន២០៣ ដោយលើកឡើងពីភាពខុសគ្នា និងបញ្ហាប្រឈមនានា។ តាមរយៈការរកឃើញសំខាន់ៗមានលក្ខណៈស្រដៀងគ្នាទៅនឹងក្របខណ្ឌអន្តរជាតិ និងការស្រាវជ្រាវរបស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ដើម្បីទទួលបានការយល់ដឹងឱ្យកាន់តែច្បាស់អំពីបរិបទដ៏ទូលំទូលាយ និងដំណោះស្រាយដែលជាសក្តានុពលសម្រាប់ការកែលម្អការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងរាជធានីភ្នំពេញ។ យោងទៅលើការស្រាវជ្រាវរបស់ UNDP ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង និងក្របខ័ណ្ឌអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុអាចផ្តល់នូវការណែនាំដ៏ទូលំទូលាយ និងជាករណីសិក្សាលើការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងប្រកបដោយប្រសិទ្ធភាពនៅទូទាំងពិភពលោក។



*រូបភាពទី២ ៖ គំនរសំរាមនៅខាងក្រោមផ្ទះប្រជាពលរដ្ឋ នៅទីតាំងលំនៅឋានក្រីក្រ*

# ២. ទិដ្ឋភាពនៃច្បាប់ជាតិ គោលនយោបាយ និងបទប្បញ្ញត្តិ

ច្បាប់ជាតិ គោលនយោបាយ និងបទប្បញ្ញត្តិនានាទាក់ទងនឹងការគ្រប់គ្រងសំរាម សំណល់រឹង បានរៀបចំឡើងក្នុងគោលបំណងការពារ និងលើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពសាធារណៈ តាមរយៈការទប់ស្កាត់ ការកាត់បន្ថយ និងការគ្រប់គ្រងការបំពុល។ បទដ្ឋានគតិយុត្តទាំងនេះក៏ជានាដល់ការអភិរក្ស ការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជាផងដែរ ។ ខាងក្រោមនេះជាការសង្ខេបនៃច្បាប់ជាតិ គោលនយោបាយ និងបទប្បញ្ញត្តិទាក់ទងនឹង ការគ្រប់គ្រងសំរាម សំណល់រឹងក្នុងប្រទេសកម្ពុជា៖

### ២.១) ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

នៅក្នុងច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ[១] មានមាត្រាមួយចំនួនទាក់ទងនឹងការគ្រប់គ្រងសំរាម សំណល់រឹង៖

មាត្រា ១២ក្នុងចំណុចទី១ បានបញ្ជាក់ច្បាស់អំពី ការចងក្រងបញ្ជីសារពើភ័ណ្ឌពី ប្រភព ប្រភេទ និងបរិមាណនៃសារធាតុបំពុល និងសំណល់ដែលបាននាំចូលបង្កើតឡើង ដឹងជញ្ជូន កែច្នៃឡើងវិញ បានប្រព្រឹត្តកម្ម រក្សាទុក បោះបង់ចោល ឬបញ្ចេញចោលទៅក្នុងអាកាស ទឹក ដី ឬលើដី។

មាត្រា១៦ ក្រសួងបរិស្ថានត្រូវផ្តល់ជូនតាមសំណូមពររបស់សាធារណជននូវព័ត៌មានពីសកម្មភាពរបស់ខ្លួននឹងត្រូវលើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណជនក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

### ២.២) គោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជនឆ្នាំ២០២០ ដល់ ២០៣០

នៅក្នុងគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជនឆ្នាំ២០២០ ដល់ ២០៣០[២] មានចំណុចសំខាន់ៗចំនួនបីទាក់ទងនឹងការគ្រប់គ្រងសំរាម សំណល់រឹង៖

ទី១. យុទ្ធសាស្ត្រនៃការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលរាជធានី ក្រុង និងស្រុកទាក់ទងនឹងវិធានការរយៈពេលខ្លី (១-២ឆ្នាំ)បានផ្តោតលើចំណុច៖

- ❒ រៀបចំយន្តការផ្តល់សេវាគ្រប់គ្រង សំរាម សំណល់រឹង ទីប្រជុំជន នៅក្នុងដែនសមត្ថកិច្ចគ្រប់គ្រង
- ❒ រៀបចំ និងអនុវត្តកម្មវិធីញែកសំរាមសំណល់រឹង ទីប្រជុំជន ចាប់ពីដើមខ្សែដល់ចុងខ្សែជាមួយនឹងការដឹកជញ្ជូនដាច់ដោយឡែក។
- ❒ អនុវត្តវិធានការកាត់បន្ថយ និងលុបបំបាត់ការបោះចោលសំរាម សំណល់រឹងប្រជុំជនដែលមិនរៀបរយនៅតាមទីសាធារណៈ និងទីតាំងឯកជន។

ទី២. ផែនការសកម្មភាព និងដំណើរការអនុវត្តគោលនយោបាយក្នុងការរៀបចំយន្តការស្ថានភាព និងការបង្កើតក្របខណ្ឌគតិយុត្តនៃថ្នាក់ក្រោមជាតិបានដាក់ចេញនូវសកម្មភាព៖

---

១ ក្រសួងបរិស្ថាន ច្បាប់ស្តីពីការការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ តាមរយៈ៖ https://shorturl.at/zQ5cX

២ ក្រសួងបរិស្ថាន គោលនយោបាយស្តីពីការគ្រប់គ្រងសំណល់រឹង ទីប្រជុំជនឆ្នាំ២០២០ ដល់២០៣០ តាមរយៈ៖ https://www.moe.gov.kh/wp-content/uploads/2021/02/160221.pdf

- ❒ បង្កើតអង្គភាព ឬការិយាល័យចំណុះរដ្ឋបាលថ្នាក់រាជធានី ក្រុង និងស្រុកក្នុងការទទួលខុសត្រូវអនុវត្តការផ្ទេរមុខគ្រប់គ្រងផែនការសកម្មភាព និងប្រតិបត្តិការនានា។
- ❒ បង្កើតយន្តការផ្តល់សេវាសម្អាត ប្រមូលដឹកជញ្ជូន និងទុកដាក់សំរាម សំណល់រឹងនៅទីលានទុកដាក់សំរាម សំណល់រឹងនៅក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន។
- ❒ ជម្រុញឱ្យមានការចូលរួមឱ្យបានច្រើនពីសំណាក់ក្រុមហ៊ុនដែលផ្តល់សេវាសម្អាតប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងដើម្បីជានាបាននូវយន្តការនៃការប្រកួតប្រជែងសម្រាប់រាជធានីភ្នំពេញ (ទៅតាមបរិមាណ និងដង់ស៊ីតេប្រជាពលរដ្ឋខ្ពស់)។

ទី៣.ចំពោះស្ថាប័នទទួលខុសត្រូវលើការអនុវត្តគោលនយោបាយគ្រប់គ្រងសំរាម សំណល់រឹងនេះ ជាពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែរៀបចំកម្មវិធីបណ្តុះបណ្តាល ការអប់រំ និងផ្សព្វផ្សាយចំណេះដឹងដល់សាធារណជនអំពីការគ្រប់គ្រងសំរាម សំណល់រឹង ប្រកបដោយអនាម័យ និងសុវត្ថិភាពបរិស្ថាន។

## ២.៣) បទប្បញ្ញត្តិនានា

- ❒ អនុក្រឹត្យលេខ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងឆ្នាំ១៩៩៩[៣]
- ❒ សេចក្តីជូនដំណឹង ស្តីពីការផ្លាស់ប្តូរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម សំណល់រឹង និងសំរាម សំណល់រឹងរាជធានីភ្នំពេញមកសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរាជធានីភ្នំពេញ (ស.ស.ភ)វិញ[៤]
- ❒ អនុក្រឹត្យលេខ ០៣អនក្រ.បកចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ ស្តីអំពីការបង្កើតសហគ្រាស[៥]
- ❒ គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ[៦]
- ❒ លិខិតផ្សព្វផ្សាយស្តីពីការអញ្ជើញចូលរួមដេញថ្លៃ លើការផ្តល់សេវាកម្ម និងដឹកជញ្ជូនសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ
- ❒ សេចក្តីណែនាំស្តីពីការគ្រប់គ្រងសំណាល់រឹងនៅរាជធានីភ្នំពេញ ឆ្នាំ២០២១[៧]
- ❒ សេចក្តីជូនដំណឹងស្តីពីការផ្លាស់ប្តូរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន[៨]

---

៣ អនុក្រឹត្យលេខ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹងឆ្នាំ១៩៩៩ តាមរយៈ៖https://shorturl.at/WUV0k

៤ សាលារាជធានីភ្នំពេញ លេខ០០២ ឆ្នាំ២០២៤ សជណ.ស សេចក្តីជូនដំណឹងស្តីពីការផ្លាស់ប្តូរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញមកសហគ្រាសគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនរាជធានីភ្នំពេញ (ស.ស.ភ)វិញ តាមរយៈ៖ https://shorturl.at/HkWbm

៥ អនុក្រឹត្យលេ៣ ០៣អនក្រ.បកចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ ស្តីអំពីការបង្កើតសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញ" តាមរយៈ៖https://epa.moe.gov.kh/posts/view/document-dswm/16590039915

៦ សាលារាជធានីភ្នំពេញ លិខិតផ្សព្វផ្សាយស្តីពីការអញ្ជើញចូលរួមដេញថ្លៃ លើការផ្តល់សេវាកម្ម និងដឹកជញ្ជូនសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ តាមរយៈ៖ https://phnompenh.gov.kh/en/news-press-releases/post/ann250220/

៧ សាលារាជធានីភ្នំពេញ សេចក្តីណែនាំស្តីពីការគ្រប់គ្រងសំណាល់រឹងនៅរាជធានីភ្នំពេញ ឆ្នាំ២០២១ តាមរយៈ៖https://phnompenh.gov.kh/en/news-press-releases/post/ann16921e/

៨ អង្គការទិន្នន័យអភិវឌ្ឍ សេចក្តីជូនដំណឹងស្តីពីការផ្លាស់ប្តូរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ពីរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹង រាជធានីភ្នំពេញ មកសហគ្រាសគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញវិញ៖ https://shorturl.at/7GnvV

# ៣. ទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌអន្តរជាតិទាក់ទងនឹងការគ្រប់គ្រងសំរាម សំណល់រឹង

ការគ្រប់គ្រងសំរាម សំណល់រឹងក្នុងទីក្រុង គឺជា បញ្ហាសំខាន់ក្នុងអភិបាលកិច្ចបរិស្ថានសហសម័យ ដោយប្រសព្វជាមួយនឹងបញ្ហាប្រឈមជាសកលដូចជាការប្រែប្រួលអាកាសធាតុ សុខភាពសាធារណៈ និងការអភិវឌ្ឍប្រកបដោយចីរភាព។ នៅក្នុងពិភពទីក្រុងកាន់តែខ្លាំងឡើង ទីក្រុងនានា ប្រឈមមុខនឹងសម្ពាធកាន់តែខ្លាំង ដើម្បីគ្រប់គ្រងបរិមាណដ៏ច្រើននៃសំរាម សំណល់រឹងដែលបង្កើតឡើងដោយការកើនឡើងនៃចំនួនប្រជាជន។ នៅក្នុងបរិបទនេះ ច្បាប់អន្តរជាតិ សន្ធិសញ្ញា និងក្របខ័ណ្ឌផ្សេងៗបានលេចចេញឡើង ដោយផ្តល់ការណែនាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងប្រកបដោយប្រសិទ្ធភាព និងបរិស្ថានល្អ។ ឧបករណ៍អន្តរជាតិទាំងនេះ ស្វែងរកការចុះសម្រុងគ្នានៃការអនុវត្តឆ្លងកាត់ព្រំដែនកំណត់ស្តង់ដារ សម្រាប់ការកាត់បន្ថយសំរាម សំណល់រឹង និងធានាការអនុលោមតាមការការពារបរិស្ថាន ដូច្នេះឧបករណ៍អន្តរជាតិនេះ ដើរតួយ៉ាងសំខាន់ក្នុងការរៀបចំគោលនយោបាយគ្រប់គ្រងសំរាម សំណល់រឹងថ្នាក់ជាតិ។

ខាងក្រោមនេះ គឺជាក្របខ័ណ្ឌអន្តរជាតិដែលពាក់ព័ន្ធច្រើននឹងការជូនដំណឹងអំពីការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងក្នុងទីក្រុង ជាពិសេសក្នុងបរិបទនៃទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ដោយបង្ហាញពីផលប៉ះពាល់របស់ពួកគេចំពោះអភិបាលកិច្ចទីក្រុង និរន្តរភាព និងសុខភាពសាធារណៈ។

**៣.១) អនុសញ្ញា Basel ស្តីពីការគ្រប់គ្រងចលនាឆ្លងដែននៃសំរាម សំណល់រឹងគ្រោះថ្នាក់ និងការចោលរបស់ពួកគេ (១៩)[៩]៖** អនុសញ្ញា Basel ត្រូវបានចាត់ទុកយ៉ាងទូលំទូលាយថាជាមូលដ្ឋានគ្រឹះនៃច្បាប់បរិស្ថានអន្តរជាតិទាក់ទងនឹងការគ្រប់គ្រងសំរាម សំណល់រឹងគ្រោះថ្នាក់។ គោលបំណងចម្បងរបស់វាគឺដើម្បីគ្រប់គ្រងចលនាឆ្លងដែននៃសំរាម សំណល់រឹងគ្រោះថ្នាក់ និងធានាការចោលក្នុងលក្ខណៈបរិស្ថាន។ អនុសញ្ញានេះត្រូវបានអនុម័ត ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកំពុងកើនឡើងនៃការដឹកជញ្ជូនសំរាម សំណល់រឹងគ្រោះថ្នាក់ពីប្រទេសអភិវឌ្ឍន៍ទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលជារឿយៗត្រូវបានក្លែងបន្លំថាជាការកែច្នៃឡើងវិញ ឬការចោលក្នុងតម្លៃទាប។ វាដាក់ទំនួលខុសត្រូវលើប្រទេសនាំចេញសំរាម សំណល់រឹង ដើម្បីធានាថាសំរាម សំណល់រឹងគ្រោះថ្នាក់ត្រូវបានចាត់ចែង និងបោះចោលដោយអនុលោមតាមស្តង់ដារបរិស្ថានដ៏តឹងរ៉ឹង។

ទោះបីជាអនុសញ្ញា Basel ផ្តោតជាពិសេសទៅលើសំរាម សំណល់រឹងគ្រោះថ្នាក់ក៏ដោយ គោលការណ៍ទូលំទូលាយនៃការគ្រប់គ្រងបរិស្ថានអាចអនុវត្តបានចំពោះការគ្រប់គ្រងសំរាម សំណល់រឹងរបស់ក្រុង។ ដោយសង្កត់ធ្ងន់លើការបន្ថយសំរាម សំណល់រឹង និងគោលការណ៍ប្រុងប្រយ័ត្ន អនុសញ្ញាលើកទឹកចិត្តឱ្យរាជរដ្ឋាភិបាលអនុម័តគោលនយោបាយ ដែលកាត់បន្ថយការបង្កើត

---

៩ អនុសញ្ញា Basel ស្តីពីការគ្រប់គ្រងចលនាឆ្លងដែននៃសំណល់រឹងគ្រោះថ្នាក់ និងការចោលរបស់ពួកគេ (១៩) តាមរយៈ៖https://www.basel.int/theconvention/overview/tabid/1271/default.aspx

សំរាម សំណល់រឹងគ្រប់ប្រភេទ រួមទាំងសំរាម សំណល់រឹងរបស់ក្រុង។ករណីទីក្រុងភ្នំពេញ ការប្រកាន់ខ្ជាប់នូវអនុសញ្ញា Basel អាចផ្តល់នូវក្របខ័ណ្ឌច្បាប់សម្រាប់កាត់បន្ថយហានិភ័យបរិស្ថានដែលទាក់ទងនឹងការចោលសំរាម សំណល់រឹងមិនត្រឹមត្រូវ ជាពិសេសនៅក្នុងការតាំងទីលំនៅក្នុងទីក្រុង។

## ៣.២) កិច្ចព្រមព្រៀងទីក្រុងប៉ារីស (២០១៥)

៖កិច្ចព្រមព្រៀងទីក្រុងប៉ារីស[១០] ក្រោមអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) តំណាងឱ្យការប្តេជ្ញាចិត្តជា សកលក្នុងការកំណត់ការកើនឡើងសីតុណ្ហភាព និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ខណៈពេលដែលកិច្ចព្រមព្រៀងផ្តោតជាចម្បងលើការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ វាក៏មានផលប៉ះពាល់យ៉ាងសំខាន់សម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងផងដែរ។ ការបំភាយឧស្ម័នមេតានចេញពីកន្លែងចាក់សំរាម សំណល់រឹង ដែលជាវិធីសាស្រ្តទូទៅនៃការចោលសំរាម សំណល់រឹងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ គឺជាប្រភពដ៏សំខាន់នៃឧស្ម័នផ្ទះកញ្ចក់ និងរួមចំណែកដល់ការឡើងកំដៅផែនដី។

កិច្ចព្រមព្រៀងទីក្រុងប៉ារីស បានអនុវត្តការតស៊ូមតិសម្រាប់ការអនុវត្តការអភិវឌ្ឍន៍ប្រកបដោយចីរភាព រួមទាំងការលើកកម្ពស់សេដ្ឋកិច្ចរាងជារង្វង់ ដែលកាត់បន្ថយសំរាម សំណល់រឹង និងកាត់បន្ថយការបំភាយឧស្ម័ន។ ប្រទេសដែលបានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងនេះត្រូវបានលើកទឹកចិត្តឱ្យអនុម័តគោលនយោបាយគ្រប់គ្រងសំរាម សំណល់រឹងដែលគាំទ្រការផ្លាស់ប្តូរទៅជាសេដ្ឋកិច្ចដែលមានកាបូនទាប។ ប្រសិនបើយោងតាមកិច្ចព្រមព្រៀងនេះ ទីក្រុងភ្នំពេញត្រូវកាត់បន្ថយការប្រើប្រាស់កន្លែងចាក់សំរាម សំណល់រឹង ដោយលើកទឹកចិត្តឱ្យមានការកែច្នៃឡើងវិញ និងគ្រប់គ្រងសំរាម សំណល់រឹងសរីរាង្គកាន់តែមានប្រសិទ្ធភាព ដើម្បីកាត់បន្ថយការបំភាយឧស្ម័នមេតាន។ ការតម្រឹមតាមគោលដៅនៃកិច្ចព្រមព្រៀងនេះនឹងមិនត្រឹមតែរួមចំណែកដល់ការប្តេជ្ញាចិត្តអាកាសធាតុរបស់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោះស្រាយកង្វល់សុខភាពសាធារណៈក្នុងតំបន់ទាក់ទងនឹងការប្រមូលផ្តុំសំរាម សំណល់រឹង និងការបំពុលរបស់វាផងដែរ។

## ៣.៣) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (២០១៥)

៖ របៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ដែលត្រូវបានអនុម័តដោយរដ្ឋសមាជិកអង្គការសហប្រជាជាតិទាំងអស់ រួមមានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព[១១] ចំនួន ១៧ ដែលដោះស្រាយបញ្ហាប្រឈមជាសកលជាច្រើន រួមទាំងនិរន្តរភាពបរិស្ថាន ការលុបបំបាត់ភាពក្រីក្រ និងសុខភាព។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពជាច្រើនត្រូវបានទាក់ទងដោយផ្ទាល់ទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹង ជាពិសេស គោលដៅទី១១ (ទីក្រុង និងសហគមន៍ប្រកបដោយនិរន្តរភាព) និង គោលដៅទី ១២ (ការប្រើប្រាស់ និងផលិតកម្មប្រកបដោយការទទួលខុសត្រូវ) (អង្គការសហប្រជាជាតិឆ្នាំ ២០១៥)។

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១១ សង្កត់ធ្ងន់លើតម្រូវការកាត់បន្ថយផល

---

១០ UNFCCC កិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ តាមរយៈ៖ //unfccc.int/sites/default/files/resource/parisagreement_publication.pdf

១១ United Nations គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០១៥ តាមរយៈ៖ https://sdgs.un.org/goals

ប៉ះពាល់បរិស្ថាននៃទីក្រុង ដោយផ្តោតជាពិសេសលើការកែលម្អការគ្រប់គ្រងសំរាម សំណល់រឹងក្រុង។ វាអំពាវនាវឱ្យមានការកាត់បន្ថយការបំពុលខ្យល់ និងទឹកដែលបណ្តាលមកពីសំរាម សំណល់រឹង ដោយភ្ជាប់ការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទៅនឹងការព្រួយបារម្ភកាន់តែទូលំទូលាយអំពីការរស់នៅ និងនិរន្តរភាពទីក្រុង។

គោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាព ទី១២ ផ្តោតលើការកាត់បន្ថយការបង្កើតសំរាម សំណល់រឹងតាមរយៈការការពារការកាត់បន្ថយ ការកែច្នៃឡើងវិញ និងការប្រើប្រាស់ឡើងវិញ។ គោលដៅទាំងនេះ តស៊ូមតិសម្រាប់ការផ្លាស់ប្តូរឆ្ពោះទៅរកគំរូនៃការប្រើប្រាស់ប្រកបដោយនិរន្តរភាពជាងមុនកាត់បន្ថយសំរាម សំណល់រឹង និងបន្តរៀបចំសម្ភារៈឡើងវិញ ដើម្បីបង្កើតសេដ្ឋកិច្ចរាងជារង្វង់។

យោងតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ជំរុញឱ្យអ្នកបង្កើតគោលនយោបាយបញ្ចូលការគ្រប់គ្រងសំរាម សំណល់រឹងទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ទូលំទូលាយ។ តាមរយៈការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងរបស់ភ្នំពេញជាមួយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទី១១ និងទី១២ ទីក្រុងអាចកែលម្អការអនុវត្តបរិស្ថាន លើកកម្ពស់សុខភាពសាធារណៈ និងលើកកម្ពស់ការអភិវឌ្ឍន៍ទីក្រុងប្រកបដោយនិរន្តរភាព។ ជាងនេះទៅទៀតគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព លើកទឹកចិត្តឱ្យមានការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសំរាម សំណល់រឹង ដែលមានសារៈសំខាន់សម្រាប់ការដោះស្រាយបញ្ហាប្រឈមដោយប្រជាជននៅទីក្រុង។

**៣.៤) កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) គោលការណ៍ណែនាំអំពីការគ្រប់គ្រងសំរាម សំណល់រឹង[១២]៖** កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) បានបង្កើតគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងដ៏ទូលំទូលាយ ដែលជាផ្នែកមួយនៃអាណត្តិដ៏ទូលំទូលាយរបស់ខ្លួន ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការការពារបរិស្ថាន។ គោលការណ៍ណែនាំតស៊ូមតិសម្រាប់ប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងរួមបញ្ចូលគ្នា ដែលពិចារណាលើវិមាត្រសង្គម បរិស្ថាន និងសេដ្ឋកិច្ច។ ពួកគេសង្កត់ធ្ងន់លើសារៈសំខាន់នៃការរួមបញ្ចូល ជាពិសេសក្នុងការដោះស្រាយតម្រូវការរបស់ប្រជាជននៅទីក្រុង ដែលខ្វះខាតជារឿយៗជួបការលំបាកការទទួលបានសេវាកម្មគ្រប់គ្រងសំរាម សំណល់រឹងមិនល្អ ឬគ្រប់គ្រាន់។

គោលការណ៍ណែនាំរបស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងទីក្រុងភ្នំពេញ ជាពិសេសក្នុងការដោះស្រាយភាពខុសគ្នារវាងទីតាំងលំនៅឋានក្រីក្រ និងទៅតាំងលំនៅឋានទូទៅ។ គោលការណ៍ណែនាំ នេះអំពាវនាវឱ្យរាជរដ្ឋាភិបាលអនុម័តវិធីសាស្ត្រចូលរួម ដោយធានាថាប្រជាពលរដ្ឋទាំងអស់មានសំឡេងនៅក្នុងដំណើរការធ្វើការសម្រេចចិត្តដែលផ្តល់ផលប៉ះពាល់ដល់ទីតាំងលំនៅឋានរបស់ពួកគេ។ ជាងនេះទៅទៀត កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិបានតស៊ូមតិសម្រាប់ភាពជាដៃគូសាធារណៈ និងឯកជន ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសំរាម សំណល់រឹង ដែលជាវិធីសាស្ត្រមួយដែលអាចបង្កើនសមត្ថភាពគ្រប់គ្រងសំរាម សំណល់រឹងរបស់ភ្នំពេញ។

១២ កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) បានបង្កើតគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសំណល់រឹង តាមរយៈ៖ https://www.undp.org/sites/g/files/zskgke326/files/publications/GuidanceNote_Solid_Waste_Management.pdf

សរុបសេចក្ដីមក ច្បាប់ និងក្របខណ្ឌអន្តរជាតិ ដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំគោលនយោបាយគ្រប់គ្រងសំរាម សំណល់រឹងជាតិ និងមូលដ្ឋាន ដោយផ្ដល់នូវគោលការណ៍ណែនាំសម្រាប់ការសម្រេចបាននូវនិរន្តរភាព កាត់បន្ថយផលប៉ះពាល់បរិស្ថាន និងការកែលម្អលទ្ធផលសុខភាពសាធារណៈ។ ក្របខណ្ឌដែលបានពិភាក្សានៅក្នុងការពិនិត្យឡើងវិញនេះ បង្កើតនូវមូលដ្ឋានគ្រឹះដ៏ទូលំទូលាយមួយសម្រាប់ពង្រឹងការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងបរិស្ថានទីក្រុង ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដូចជាកម្ពុជា។ ឧបករណ៍ដូចជាអនុសញ្ញា Basel និងកិច្ចព្រមព្រៀងទីក្រុងប៉ារីស បញ្ជាក់ពីតម្រូវការសម្រាប់ការអនុវត្តការចោលសំរាម សំណល់រឹងប្រកបដោយគុណភាព និងបរិស្ថាន ខណៈដែលគោលដៅអភិវឌ្ឍន៍ចីរភាព សង្កត់ធ្ងន់លើការកាត់បន្ថយសំរាម សំណល់រឹង ការកែច្នៃឡើងវិញ និងការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។

សម្រាប់រាជធានីភ្នំពេញ ការតម្រឹមលើគោលនយោបាយគ្រប់គ្រងសំរាម សំណល់រឹងរបស់ខ្លួនជាមួយនឹងក្របខណ្ឌអន្តរជាតិទាំងនេះ ផ្ដល់ឱកាសមួយដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការគ្រប់គ្រងទីក្រុង កាត់បន្ថយការបង្កើតសំរាម សំណល់រឹង និងលើកកម្ពស់សុខភាពសាធារណៈ។ តាមរយៈការអនុវត្តវិធីសាស្ត្រចូលរួម ការពង្រឹងរចនាសម្ព័ន្ធអភិបាលកិច្ច និងការអនុវត្តអន្តរជាតិល្អបំផុត រាជធានីភ្នំពេញអាចបង្កើតប្រព័ន្ធគ្រប់គ្រងសំណល់ប្រកបដោយនិរន្តរភាព រួមបញ្ចូល និងមានប្រសិទ្ធភាពជាងមុន ដែលផ្ដល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋទាំងអស់ ជាពិសេសសហគមន៍ងាយរងគ្រោះ។

ជាងនេះទៅទៀត គោលការណ៍ណែនាំទាំងនេះលើកទឹកចិត្តឱ្យរាជរដ្ឋាភិបាលប្រកាន់យកនូវយុទ្ធសាស្ត្រចូលរួម ដែលធានាថាប្រជាពលរដ្ឋទាំងអស់មានសំឡេងក្នុងការសម្រេចចិត្តដែលប៉ះពាល់ដល់សហគមន៍របស់ពួកគេ។ លើសពីនេះ កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) តស៊ូមតិសម្រាប់ភាពជាដៃគូសាធារណៈ និងឯកជន ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសំរាម សំណល់រឹង ដែលជាយុទ្ធសាស្ត្រមួយដែលអាចលើកកម្ពស់សមត្ថភាពគ្រប់គ្រងសំណល់នៅក្នុងរាជធានីភ្នំពេញ។

# ៤.វិធីសាស្ត្រស្រាវជ្រាវ

### ៤.១) គោលបំណងស្រាវជ្រាវ

របាយការណ៍ស្រាវជ្រាវស្តីអំពីការគ្រប់គ្រងសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ ដោយប្រៀបធៀបរវាងទីតាំងដែលជាទីតាំងលំនៅឋានក្រីក្រ និងទីតាំងលំនៅឋានទូទៅ ដែលមានគោលបំណងឈ្វេងយល់អំពីការគ្រប់គ្រងសំរាម សំណល់រឹងក្នុងមូលដ្ឋាន និងប្រៀបធៀបរវាងទីតាំងលំនៅឋានក្រីក្រ និងទីតាំងទូទៅ ដើម្បីកំណត់នូវបញ្ហាបាននឹងកំពុងប្រឈមជាក់លាក់។ របាយការណ៍ស្រាវជ្រាវនេះនឹងបង្ហាញនូវទិដ្ឋភាពចំនួនបួនសំខាន់ៗ៖ ទីមួយ ការចូលរួមអនុវត្តរបស់ប្រជាពលរដ្ឋ ទីពីរ វិធីសាស្ត្រនៃការចោលសំរាម សំណល់រឹង ទីបី ការយល់ដឹងអំពីការគ្រប់គ្រងសំរាម សំណល់រឹងជាសាធារណៈ និងទីបួន ការញែកសំរាម សំណល់រឹង។ ការរឃើញសំខាន់ៗនឹងកំណត់អនុសាសន៍ដោយបញ្ចូលវិធីសាស្ត្រ និងយុទ្ធសាស្ត្រដោះស្រាយបញ្ហាបាននឹងកំពុងប្រឈម និងផ្សព្វផ្សាយឱ្យបានដល់ភាគីពាកព័ន្ធ ដើម្បីបានជាទិន្នន័យ ឬជាព័ត៌មានដោះស្រាយបញ្ហាទាំងនោះជូនសាធារណជន និងជាការរួមចំណែកជួយឱ្យរាជធានីភ្នំពេញទទួលបានបរិស្ថានស្អាត និងអនាម័យផងដែរ។

### ៤.២) វិធីសាស្ត្រប្រមូលទិន្នន័យ

ការស្រាវជ្រាវ បានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបគុណភាព និងបែបបរិមាណ។ វិធីសាស្ត្រស្រាវជ្រាវបែបគុណភាព បានរៀបចំកិច្ចពិភាក្សាក្រុមដែលបានអញ្ជើញប្រជាពលរដ្ឋចូលរួមចន្លោះ១០ ទៅ១៥នាក់ ដើម្បីផ្ទៀងផ្ទាត់លើព័ត៌មានសំខាន់ៗមួយចំនួនក្នុងកម្រងសំណួរបែបបរិមាណ។ សម្រាប់ការសម្ភាសបែបបរិមាណគឺរៀបចំកម្រងសំណួរលម្អិតអំពីស្ថានភាពទាំងអស់ក្នុងដំណើរការស្រាវជ្រាវ ដើម្បីទទួលបានព័ត៌មានស្ថិតិ ជាតួលេខ ឬភាគរយ។ ការសម្ភាសបែបបរិមាណត្រូវសម្ភាសតាមខ្នងផ្ទះ ដោយធ្វើការជ្រើសរើសចន្លោះពីបីទៅប្រាំខ្នងម្តង និងប្រើប្រាស់រយៈពេលសម្ភាសចន្លោះពី ៣០នាទី ទៅ៤០នាទី សម្រាប់អ្នកផ្តល់បទសម្ភាសម្នាក់។ ជាងនេះទៀត កិច្ចការស្រាវជ្រាវនេះក៏បានអង្កេតស្ថានភាពទូទៅនៅមូលដ្ឋានដែលបានចុះប្រមូលព័ត៌មាន ឬទិន្នន័យផងដែរ។

### ៤.៣) ទំហំសំណាកដែលបានជ្រើសរើស

តាមរយៈបទពិសោធការចុះអនុវត្តការងារជាមួយសហគមន៍គោលដៅទាំង១៤ទីតាំង អង្គការសមាគមធាងត្នោតសង្កេតឃើញថា សហគមន៍ទាំងនេះ កំពុងប្រឈមនឹងបញ្ហាការគ្រប់គ្រងសំរាម សំណល់រឹងនៅមូលដ្ឋានដែលពួកគេបានរស់នៅ។ ដូច្នេះទើបអង្គការសមាគមធាងត្នោតលើកយកជាប្រធានបទស្រាវជ្រាវ ដើម្បីកំណត់ឱ្យឃើញនូវបញ្ហាប្រឈមជាក់ស្តែង។ ការកំណត់ទំហំសំណាកគឺប្រើប្រាស់រូបមន្តយ៉ាមីនតារ៉ូ (YAMANE TARO, N: ១៣២០HH & e: ១០%) ឆ្នាំ១៩៦៧[១៣] ដើម្បីគណនាទំហំសំណាកសម្រាប់អ្នកផ្តល់បទសម្ភាសនៅតំបន់គោលដៅខាងលើនេះ។ ដើម្បីធានាថាទីតាំងលំនៅឋានក្រីក្រ និងទីតាំងលំនៅឋានទូទៅមានស្ថានភាពរស់នៅដូចគ្នា ឬខុសគ្នាយ៉ាងណានោះ យើងកំណត់យកទីតាំងលំនៅឋានក្រីក្រចំនួន ១៤ទីតាំង និងទីតាំងលំនៅឋានទូទៅដែលរស់នៅភូមិក្បែរទីតាំងលំនៅឋានក្រីក្រចំនួន១៤ មកធ្វើការស្រាវជ្រាវ។ ទីតាំងទាំងនេះ ស្ថិតនៅក្នុងខណ្ឌចំនួន៦រួមមាន ខណ្ឌចំការមន ខណ្ឌមានជ័យ ខណ្ឌឫស្សីកែវ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌដង្កោនិងខណ្ឌច្បារអំពៅ។

---

១៣ Tenato, How to Calculate Sample Size for a Survey, 2022, Access thought link: https://www.tenato.com/market-research/what-is-the-ideal-sample-size-for-a-survey/

តារាង ១ ទីតាំងលំនៅឋានក្រីក្រគោលដៅដែលបានជ្រើសរើសសម្រាប់ការស្រាវជ្រាវ

| តំបន់គោលដៅស្រាវជ្រាវ | ទីតាំងលំនៅឋានក្រីក្រ | ចំនួនអ្នកផ្តល់បទសម្ភាស |
|---|---|---|
| ចំការមន | សាមគ្គីរុងរឿង | ៧ |
| | បឹងត្របែកភូមិ៤ | ៩ |
| មានជ័យ | ព្រែកតាគង់៣ | ៣ |
| | រស្មីសាមគ្គី | ៦ |
| ឫស្សីកែវ | ស្ត្រីក្លាហាន | ៤ |
| | បុរីដើមស្រល់ | ៨ |
| ពោធិ៍សែនជ័យ | ពង្រសែនជ័យ | ១៥ |
| ដង្កោ | រលួសជើងឯក | ៦ |
| ច្បារអំពៅ | រីកចំរើន | ៦ |
| | បឹងឈូកមានជ័យថ្មី២ | ៣ |
| | ឫស្សីស្រស់ | ១០ |
| | ស្ទួសាន | ១៤ |
| | ចំរើន | ៦ |
| | វាលស្បូវ | ៧ |
| សរុប | | ១០៤ |



*រូបភាពទី៤៖ ទីតាំងលំនៅឋានក្រីក្រដែលបានផ្តល់បទសម្ភាស*

តារាង ២  ទីតាំងលំនៅឋានទូទៅ ដែលបានជ្រើសរើសសម្រាប់ការស្រាវជ្រាវ

| តំបន់គោលដៅស្រាវជ្រាវ | ទីតាំងលំនៅឋានទូទៅ | ចំនួនអ្នកផ្តល់បទសម្ភាស |
|---|---|---|
| ចំការមន | ភូមិ៤ | ៧ |
| | ភូមិ៥ | ៧ |
| មានជ័យ | ភូមិព្រែកតាគង់២ | ៩ |
| | ភូមិឬស្សី២ | ៣ |
| ឫស្សីកែវ | ភូមិស្ពានខ្ពស់ | ៦ |
| | ភូមិមិត្តភាព (គីឡូម៉ែត្រលេខ៦) | ៤ |
| ពោធិ៍សែនជ័យ | ភូមិ ទួលពង្រ | ៨ |
| ដង្កោ | ភូមិស្រុកចេក | ១៥ |
| ច្បារអំពៅ | ភូមិព្រែកតាពៅ | ៦ |
| | ភូមិតាង៉ូវ កណ្តាល | ៦ |
| | ភូមិកោះនរា | ៣ |
| | ភូមិកណ្តាល | ១០ |
| | ភូមិដើមស្លែង | ៩ |
| | ភូមិព្រែកធំ២ | ៦ |
| សរុប | | ៩៩ |



*រូបភាពទី៣៖ ទីតាំងលំនៅឋានទូទៅដែលបានផ្តល់បទសម្ភាស*

តារាង ៣ ទំហំសំណាកសម្រាប់កិច្ចការស្រាវជ្រាវនេះ

| អ្នកផ្តល់បទសម្ភាស | ចំនួន | ភាគរយ |
|---|---|---|
| ទីតាំងលំនៅឋានក្រីក្រ | ១០៤ | ៤៨ |
| ទីតាំងលំនៅឋានទូទៅ | ៩៩ | ៤៦ |
| ប្រធានភូមិ | ១០ | ៥ |
| មន្ត្រីសង្កាត់ | ១ | 0.៥ |
| ក្រុមហ៊ុនប្រមូលសំរាម សំណល់រឹង | ១ | 0.៥ |
| សរុប | ២១៥ | ១00 |

### ៤.៤) ការវិភាគទិន្នន័យ

ដំណើរការស្រាវជ្រាវនេះ បានបង្កើតកម្រងសំណួរតាមរយៈកម្មវិធីប្រមូលទិន្នន័យអេឡិចត្រូនិចឈ្មោះថា កូបូធូលបក់ “kobo toolbox”។ ការរៀបចំសម្អាតទិន្នន័យ គឺប្រើប្រាស់កម្មវិធីម៉ាក្រូសូហ្វ អិចសែល “Microsoft Excel” និងធ្វើការវិភាគ និងប្រៀបធៀបទិន្នន័យតាមរយៈកម្មវិធី អេសភីអេសអេស “SPSS”។

### ៤.៥) វិសាលភាពសម្រាប់ការស្រាវជ្រាវ

របាយការណ៍ស្រាវជ្រាវនឹងធ្វើការពិនិត្យផ្ទៀងផ្ទាត់ជាមួយរបាយការណ៍ស្រាវជ្រាវមុនៗ ដែលមានលក្ខណៈស្រដៀងគ្នាជាមួយនឹងស្ថាប័ននានា ទាំងកម្រិតថ្នាក់ជាតិ និងតំបន់ និងឯកសារច្បាប់នានា គោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលទាក់ទងនឹងការគ្រប់គ្រងសំរាម សំណល់រឹង។ ឯកសារទាំងនោះអាចរកបានតាមរយៈ គេហទំព័រផ្លូវការរបស់ក្រសួងពាក់ព័ន្ធ និងស្ថាប័ននានា។ យ៉ាងណាមិញ ព័ត៌មានមួយចំនួន ឬឯកសារសំខាន់នានា ក៏ត្រូវការកិច្ចសហការពីក្រសួងពាក់ព័ន្ធផងដែរ ដើម្បីទទួលបានព័ត៌មានគ្រប់គ្រាន់សម្រាប់ការវិភាគដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ លើបញ្ហាប្រឈមនានា ដែលបានលើកឡើងក្នុងដំណើរការស្រាវជ្រាវមួយនេះ។

### ៤.៦) ព័ត៌មានប្រជាសាស្ត្រ

ប្រជាពលរដ្ឋដែលមកពីទីតាំងលំនៅឋានក្រីក្រចំនួន១៤ទីតាំង ភូមិចំនួន១៤ និងក្នុងចំនួន៦ខណ្ឌ បានផ្តល់បទសម្ភាសជាស្រីចំនួន ១៤៩នាក់ និងប្រុសចំនួន ៥៤នាក់។ អ្នកផ្តល់បទមានអាយុចាប់ពីអាយុ១៦ឆ្នាំ មានចំនួន២នាក់ អាយុចន្លោះពី១៧ឆ្នាំ ដល់៣០ឆ្នាំ មានចំនួន២៤នាក់ អាយុចន្លោះពី ៣១ឆ្នាំ ដល់៤៥ឆ្នាំ មានចំនួន៨៧នាក់ និងអាយុច្រើនជាង ៤៥ឆ្នាំមានចំនួន៩០នាក់។

ពួកគេបានរស់នៅទីតាំងផ្តល់បទសម្ភាសក្នុងរយៈពេលក្រោម១៥ឆ្នាំ មានចំនួន១៣៤នាក់ រយៈពេលចាប់ពី ១៦ឆ្នាំ ដល់៣៥ឆ្នាំ មានចំនួន១០៨នាក់ និងអ្នកដែលកំពុងរស់នៅមានរយៈពេលច្រើនជាង ៣៥ឆ្នាំ មានចំនួន ៦០នាក់។ អ្នកផ្តល់បទសម្ភាសជាស្ត្រីមេផ្ទះ ២៣ភាគរយ អ្នកប្រកបមុខរបរលក់ដូរចាប់ហួយ ៣៦ភាគរយ និងអ្នកប្រកបមុខរបរផ្សេងៗទៀត ៤១ភាគរយ មានដូចជា កម្មករសំណង់ កម្មកររោងចក្រ ជាងកាត់ដេរតាមផ្ទះ ជាងជួសជុលម៉ូតូ ជាងកាត់សក់ ជាងជួលជុលទូរស័ព្ទ ជាងឈើ ជាងជួលជុលម៉ាញ៉េ ជាងអ៊ុតសក់ អ្នកស៊ីឈ្នួលបកខ្ទឹម អ្នកស៊ីឈ្នួលបោកខោអាវ អ្នកលក់ចង្រិត អ្នកបើករឺង (ភ្នាក់ងាររឺង) អ្នករត់ឌុប អ្នករើសអេតចាយ អ្នកលក់បន្លែ អ្នកលក់ចំណីអាហារ អ្នកលាងចាននៅហាងគុយទាវ អ្នកដឹកអីវ៉ាន់ អ្នកបញ្ចូលសម្លេង អ្នកដេរវត្ថុអនុស្សាវរីយ៍ អ្នកបញ្ចូលហ្គាស កសិករចិញ្ចឹមគោ ចុងភៅ បុគ្គលិកក្រុមហ៊ុន សិស្ស និងមន្ត្រីរាជការ។

តារាង ៤ អាយុអ្នកផ្តល់បទសម្ភាស

| វ័យអ្នកផ្តល់បទសម្ភាស | ទីតាំងលំនៅឋានក្រីក្រ | ទីតាំងលំនៅឋានទូទៅ |
|---|---|---|
| ចាប់ពី ១៦ឆ្នាំ | ១ | ១ |
| ១៧ឆ្នាំ - ៣០ឆ្នាំ | ៦ | ១៨ |
| ៣១ឆ្នាំ - ៤៥ឆ្នាំ | ៤០ | ៤៧ |
| ច្រើនជាង ៤៥ឆ្នាំ | ៥៧ | ៣៣ |
| សរុប | ១០៤ | ៩៩ |

តារាង ៥ រយៈពេលរស់នៅទីតាំងដែលបានផ្តល់បទសម្ភាស

| រយៈពេលរស់នៅ<br>នៃទីតាំងអ្នកផ្តល់បទសម្ភាស | ទីតាំងលំនៅឋានក្រីក្រ | ទីតាំងលំនៅឋានទូទៅ |
|---|---|---|
| ០១ឆ្នាំ - ០៥ឆ្នាំ | ២៧ | ១៨ |
| ០៦ឆ្នាំ - ១០ឆ្នាំ | ៤៥ | ២៤ |
| ១១ឆ្នាំ - ១៥ឆ្នាំ | ១៣ | ៧ |
| ១៦ឆ្នាំ - ២០ឆ្នាំ | ៣២ | ១៤ |
| ២១ឆ្នាំ - ២៥ឆ្នាំ | ១៧ | ៥ |
| ២៦ឆ្នាំ - ៣០ឆ្នាំ | ១៦ | ៥ |
| ៣១ឆ្នាំ - ៣៥ឆ្នាំ | ១៣ | ៦ |
| ច្រើនជាង ៣៥ឆ្នាំ | ៤០ | ២០ |
| សរុប | ១០៤ | ៩៩ |




រូបភាពទី៥៖ គំនរសំរាមបានគេទុកមុខផ្ទះរង់ចាំឡានស៊ីផ្លេទើបប្រមូលយកទៅចោល

# ៥. លទ្ធផលនៃការស្រាវជ្រាវសំខាន់ៗ

### ៥.១) ទីតាំងចោលសំរាម សំណល់រឹង

ចំនួន១២៨នាក់នៃអ្នកផ្តល់បទសម្ភាសសរុប២០៣នាក់ បានប្រាប់ថាពួកគេមិនមានទីតាំងសម្រាប់ចោលសំរាម សំណល់រឹងប្រចាំថ្ងៃនោះទេ ក្នុងនោះ ចំនួន៧៥នាក់ ជាប្រជាពលរដ្ឋរស់នៅទីតាំងទូទៅ និងចំនួន៥៣នាក់មកពីទីតាំងលំនៅឋានក្រីក្រ។ ប្រជាពលរដ្ឋរស់នៅទីតាំងទូទៅដែលបានផ្តល់បទសម្ភាស គឺរស់នៅតាមដងផ្លូវធំៗ ឬតាមបណ្តោយផ្លូវជាតិ និងមួយចំនួនទៀតតូចកំពុងរស់នៅតាមប្រកក្បែរផ្លូវជាតិដែលមានចម្ងាយប្រហែល៥០ម៉ែត្រពីផ្លូវធំប៉ុណ្ណោះ។ ពួកគេបានប្រាប់ក្នុងដំណើរការសម្ភាសថាពួកគេមិនមានទីតាំងសមរម្យដើម្បីចោលសំរាម សំណល់រឹងនោះទេ បច្ចុប្បន្នពួកគេបានចោលសំរាម សំណល់រឹងរបស់ពួកគេនៅខាងមុខផ្ទះ។ យ៉ាងណាមិញពួកគេបានកំពុងប្រឈមនឹងបញ្ហាមួយចំនួនដូចជា ការចោលសំរាម សំណល់រឹងមិនបានត្រឹមត្រូវបណ្តាលឱ្យមានជម្លោះអ្នកជិតខាង និងអ្នកជិតខាង ការវេចខ្ចប់សំរាម សំណល់រឹងមិនបានត្រឹមត្រូវ ការចោលសំរាម សំណល់រឹងលើដីទំនេររបស់គេ និងការប្រមូលមិនស្អាតរបស់បុគ្គលិកប្រមូលសំរាម សំណល់រឹង។

ដោយឡែកស្ថានភាពរបស់ទីតាំងលំនៅឋានក្រីក្របានប្រាប់ថាមិនមានទីតាំងចោលសំរាម សំណល់រឹង។ ទីតាំងដែលបានកំណត់ថាជាទីតាំងលំនៅឋានក្រីក្រនោះ គឺពួកគេរស់នៅក្នុងតំបន់មិនទាន់រៀបរយដែលមានការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ មិនមានប្លង់កម្មសិទ្ធិសម្គាល់អចលនទ្រព្យ និងមានចំនួនចាប់ពី១០ខ្នងផ្ទះឡើងទៅ។[១៤] បច្ចុប្បន្នពួកគេបានប្រឈមនឹងបញ្ហាដូចជា មិនមានទីកន្លែងទំនេរសមល្មមសម្រាប់ទុកដាក់សំរាម សំណល់រឹងនៅខាងមុខផ្ទះ ដោយសារស្ថានភាពទីតាំងភូមិសាស្ត្រតូចចង្អៀត និងផ្លូវធ្វើដំណើរចូលទីតាំងក៏តូចចង្អៀតដែលអាចចូលបានតែម៉ូតូ ឬរថយន្តខ្នាតតូចប៉ុណ្ណោះ។ មួយវិញទៀត ទីតាំងលំនៅឋានក្រីក្រមានចម្ងាយឆ្ងាយចន្លោះប្រមាណពី១០០ម៉ែត្រទៅ៥០០ម៉ែត្រពីផ្លូវធំ ឬផ្លូវជាតិឯណ្ណោះ ដូចនេះការបញ្ចេញសំរាម សំណល់រឹងមានការលំបាកខ្លាំងណាស់ ព្រោះរថយន្តប្រមូលសំរាមមិនអាចចូលដល់ទីតាំងលំនៅឋានក្រីក្រ ហើយក៏មិនមានរទេះរបស់ក្រុមហ៊ុនចូលមកប្រមូលសំរាម សំណល់រឹងដែរ ដូច្នេះស្ថានភាពលំបាកនេះ តម្រូវឱ្យពួកគេបញ្ចេញសំរាម សំណល់រឹងទាំងមានសភាពប្រញាប់ប្រញាល់ខ្លាំង នៅពេលបានលឺស៊ីផ្លេឡានដឹកសំរាមម្តងៗ។ ចំពោះករណីនេះ ស្ត្រីម្នាក់រស់នៅក្នុងទីតាំងលំនៅឋានក្រីក្របានប្រាប់ថា៖

> “ទីតាំងលំនៅឋានក្រីក្រខ្ញុំនៅក្រោយហើយជ្រៅនៅពេលបានលឺស៊ីផ្លេឡានសំរាមម្តងៗខ្ញុំត្រូវរត់ចេញពីផ្ទះទើបយកសំរាមទៅចោលទាន់ឡានហើយពេលខ្លះក៏មិនបានលឺស៊ីផ្លេឡាន សំរាមសំណល់រឹងទុកក្នុងផ្ទះក៏ស្អុយចឹងទៅ។”

---

១៤ អង្គការសមាគមធាងត្នោត របាយការណ៍ស្តីពី ការស្ទង់មតិរាជធានីភ្នំពេញ ឆ្នាំ២០១៤ តាមរយៈ៖ https://teangtnaut.org/wp-content/uploads/2014/03/STT-_201402_Phnom-Penh-Survey.pdf

ក្រាហ្វិច១ ទីតាំងទុកដាក់ ឬចោលសំរាម សំណល់រឹង




ករណីផ្សេងទៀត សម្រាប់ទីតាំងលំនៅឋានក្រីក្រខ្លះ ដែលឡានដឹកសំរាមមិនអាចចូលប្រមូលបាន និងមិនបានលឺស៊ីផ្លេឡានដឹកសំរាមនោះ ពួកគេគ្មានជម្រើសក្រៅពីគរសំរាមក្នុងផ្ទះច្រើនថ្ងៃ និងបន្តរងចាំស្តាប់ស៊ីផ្លេឡានដឹកសំរាមបន្តទៀត។

ដោយឡែកទីតាំងលំនៅឋានក្រីក្រខ្លះទៀត បានចាប់ផ្តើមទម្លាប់ចោលសំរាម សំណល់រឹងតាមរយៈសមាជិកស្ម័គ្រចិត្តដែលបានចូលប្រមូលសំរាមដោយផ្ទាល់ដោយប្រើកូនរទេះតូចមួយជារៀងរាល់ថ្ងៃ។ សមាជិកទាំងអស់នៅទីតាំងលំនៅឋានក្រីក្រ តែងតែផ្តល់ប្រាក់ឧបត្ថម្ភ ចំនួនមួយពាន់ ទៅពីរពាន់រៀល សម្រាប់ការប្រមូលម្តងៗដោយសារអ្នកប្រមូលនោះមិនមានការងារអចិន្ត្រៃយ៍ ឬទទួលបានប្រាក់ឧបត្ថម្ភពីអាជ្ញាធរ ឬក្រុមហ៊ុនប្រមូលសំរាម សំណល់រឹងនោះទេ។

### ៥.២) ការទុកដាក់សំរាម

ការទុកដាក់សំរាមសំដៅដល់ការទុកដាក់សំរាមនៅទីតាំងដែលបានកំណត់ឱ្យចោលសំរាមដោយអាជ្ញាធរមូលដ្ឋាន។ បើពិនិត្យមើលតួលេខនៃអ្នកផ្តល់បទសម្ភាសថាមានទីតាំងចោលសំរាមដែលបានកំណត់ដោយអាជ្ញាធរមូលដ្ឋាននោះមានចំនួន៧៥នាក់ ដូចនេះតាមរយៈការវិភាគឃើញថា អ្នកដែលអនុវត្តត្រឹមត្រូវ ឬបានទុកដាក់សំរាមនៅកន្លែងដែលកំណត់ឱ្យចោលនោះ មាន៥៩នាក់ ដែលស្មើនឹង៧៩% នៃចំនួនសរុប៧៥នាក់។ ដូច្នេះ មានតែចំនួន ១៦នាក់ប៉ុណ្ណោះ ដែលមានទីតាំងកំណត់ឱ្យចោលសំរាមហើយ នៅតែមិនអនុវត្តការទុកដាក់សំរាមឱ្យបានត្រឹមត្រូវ។

ចំពោះស្ថានភាពអ្នកដែលមិនមានទីតាំងចោលសំរាម ការទុកដាក់សំរាមរបស់ពួកគេមានទិន្នភាពដូចជា៖ ទីតាំងលំនៅឋានក្រីក្រមានចំនួន៥៨នាក់ ក្នុងនោះមាន ៤៦នាក់បានទុកដាក់សំរាមបណ្តោះអាសន្នក្នុងផ្ទះរបស់ពួកគេ ចំនួន៨នាក់បានចោលសំរាមនៅឯទីផ្សារ និង៤នាក់ទៀតបានចោលសំរាមនៅតាមថ្នល់ជាតិពេលយប់។

ចំណែកឯ ទីតាំងលំនៅឋានទូទៅមានចំនួន ៨៦នាក់ ប្រាប់ថាការទុកដាក់សំរាមនៅខាងមុខផ្ទះជាទីតាំងមិនបានកំណត់នោះ ទំនងជាពួកគេមិនបានដឹងថាទីតាំងខាងមុខផ្ទះរបស់

ពួកគេអនុញ្ញាតឱ្យចោលបាន ដោយគ្រាន់តែដឹងនូវម៉ោងបញ្ចាញសំរាម និងរថយន្តចាំឡានដឹកសំរាមមកប្រមូលតាមកាលវិភាគកំណត់។

ទាក់ទងនឹងករណីទុកដាក់សំរាមខុសទីតាំងនេះផងដែរ មានអ្នកផ្តល់បទសម្ភាសម្នាក់បានទទួលបានការណែនាំពីអាជ្ញាធរមូលដ្ឋានឱ្យបញ្ឈប់ការចោលសំរាមនៅទីតាំងដែលមិនបានកំណត់ (នៅតាមដងផ្លូវធ្វើដំណើរ) ព្រោះករណីនេះបណ្តាលឱ្យជះក្លិនស្អុយដល់អ្នករស់នៅក្បែរនោះ។

ករណីទំនាស់ហិង្សាប្រើប្រាស់អាវុធ (កាំបិតនិងដំបងឈើ) មួយបានកើតឡើង មូលហេតុដោយសារការទុកដាក់សំរាមបណ្តោះអាសន្ននៅខាងមុខផ្ទះក្នុងទីតាំងលំនៅឋានក្រីក្របានបំភាយក្លិនស្អុយជះដល់ផ្ទះអ្នកជិតខាងបង្កឱ្យមានការប្រើពាក្យសំដីធ្ងន់ធ្ងររហូតឈានទៅដល់ការប្រើហិង្សារវាងគ្នានិងគ្នា។ ករណីនេះក៏ទទួលបានការអន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋានផងដែរ ជាលទ្ធផលភាគីបង្កអ្នកទុកដាក់សំរាមបណ្តោះអាសន្នច្រើនថ្ងៃនោះសងជម្ងឺចិត្តដល់ភាគីជាអ្នករស់នៅជិតខាង។ ទាំងនេះសុទ្ធតែជាបញ្ហាដែលបណ្តាលមកពីការទុកដាក់សំរាម ឬការមិនមានទីតាំងសមរម្យដែលផ្តល់ភាពងាយស្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋ។

ក្រាហ្វិច២ សកម្មភាពចោលសំរាមសម្រាប់ទីតាំងដែលមិនមានការកំណត់ទីតាំងឱ្យចោលសំរាម



### ៥.៣) ការញែកសំរាម

តាមរយៈសេចក្តីណែនាំរបស់សាលារាជធានីភ្នំពេញការញែកសំរាមតម្រូវជាពីរប្រភេទ គឺសំរាមសើម និងសំរាមស្ងួត។ ចំពោះសំរាមសើមសំដៅលើសំណល់ម្ហូបអាហារ សំណល់សរីរាង្គ ផ្លែឈើ ផ្កា ដែលតម្រូវឱ្យច្រកក្នុងថង់ពណ៌ខ្មៅ និងសំរាមស្ងួតសំដៅលើ ក្រដាស ក្រដាសកាតុង ឡាំង គ្រឿងប្លាស្ទិក ជ័រ ដែក កំប៉ុងដបហើយតម្រូវច្រកក្នុងថង់ពណ៌ស។ ការស្រាវជ្រាវរកឃើញថាមានចំនួន៦៤នាក់ បានអនុវត្តការញែកសំរាមសើម និងស្ងួត និងចំនួន ១៣៩នាក់ទៀត មិនបានញែកសំរាមតាមការកំណត់នោះទេ។ ជាងនេះទៀត អ្នកដែលបានអនុវត្តការញែកសំរាមសើម និងស្ងួតហើយច្រកតាមប្រភេទពណ៌កំណត់មានតែ ៤នាក់ប៉ុណ្ណោះ ហើយពួកគេជាពលរដ្ឋដែលរស់នៅក្នុងទីតាំងលំនៅឋានក្រីក្រ។

កត្តាជម្រុញមិនអនុវត្តការញែកសំរាម មានអ្នកផ្តល់បទសម្ភាសចំនួន១៣៩នាក់ បានលើកឡើងថា ពួកគេគិតថាការញែកសំរាមនេះដោយគិតថាមិនសូវមានសារៈសំខាន់ ហើយពួកគេតែងតែសង្កេតឃើញការប្រមូលសំរាមសំណល់រឹងរបស់បុគ្គលិកក្រុមហ៊ុនផ្តល់សេវាប្រមូលសំរាមនៅប្រមូលយកសំរាមដែលមិនបានញែក និងសំរាមដែលបានញែកដាក់បញ្ចូលគ្នាតែមួយ។ ដូច្នេះបើពួកគេអនុវត្តការញែកសំរាម វាជាការចំណាយពេលមិនមានតំលៃ និងចំណាយថវិកាមិនមានប្រសិទ្ធភាព។

តារាង ៦ កត្តាជម្រុញឱ្យមានការអនុវត្តការញែកសំរាម (ចម្លើយលើសពីមួយ)

| កត្តាជម្រុញឱ្យមានការអនុវត្តការញែកសំរាម សំណល់រឹង | ទីតាំងលំនៅឋានក្រីក្រ | ទីតាំងលំនៅឋានទូទៅ |
|---|---|---|
| ការយល់ដឹងរបស់អ្នកផ្តល់បទសម្ភាសទាក់ទងនឹងការច្រក់សំរាមក្នុងថង់តែមួយគឺជាការអនុវត្តមិនល្អ | ២៧ | ១៦ |
| ការបំបែកសំរាមស្ងួតដូចជាកំប៉ុង ឬដបអាចលក់ដូរបាន | ១១ | ១៤ |
| ការទទួលការផ្សព្វផ្សាយស្តីពីការញែកសំរាមរឹងពីអាជ្ញាធរមូលដ្ឋាន | ៥ | ៤ |
| ការទទួលបានវគ្គបណ្តុះបណ្តាលស្តីពីអត្ថប្រយោជន៍នៃការញែក ឬកែច្នៃពីអង្គការក្រៅរដ្ឋាភិបាល | ៥ | ០ |
| ការយល់ថាសំរាមអាចយកមកកែច្នៃ | ១ | ១ |
| ការយល់ដឹងតាមរយៈបង្រៀននៅសាលារៀន | ០ | ១ |
| សរុប | ៤៩ | ៣៦ |

### ៥.៤) ម៉ោងបញ្ចេញសំរាម ឬចោលសំរាម

ប្រជាពលរដ្ឋចំនួន ១៧០នាក់ នៃអ្នកផ្តល់បទសម្ភាសសរុប ២០៣នាក់ បានរាយការណ៍ថាពួកគេមិនបានទទួលកាលវិភាគបញ្ចេញសំរាមនោះទេ មានតែ ៣៣នាក់ប៉ុណ្ណោះ ដែលទទួលបានកាលវិភាគបញ្ចេញសំរាម។ តាមរយៈការស្រាវជ្រាវចំនួនអ្នកបញ្ចេញសំរាមដែលត្រឹមត្រូវតាមកាលវិភាគបញ្ចេញសំរាមនោះ មានតែចំនួន២២នាក់ ស្របតាមសេចក្តីណែនាំរបស់សាលារាជធានីភ្នំពេញ[១៥] និងអ្នកបញ្ចេញសំរាមមិនត្រឹមត្រូវមានចំនួន ១៨១នាក់។

តាមការផ្ទៀងផ្ទាត់កាលវិភាគប្រមូលសំរាមរបស់ក្រុមហ៊ុនប្រមូលសំរាម និងសេចក្តីណែនាំរបស់សាលារាជធានីភ្នំពេញ៖[១៦]

ដូចនេះលទ្ធផលវិភាគ តារាងខាងក្រោម ការបញ្ចេញសំរាមដែលត្រឹមត្រូវតាមម៉ោងកំណត់ដែលបានផ្ទៀងផ្ទាត់រវាងសេចក្តីណែនាំរបស់សាលារាជធានីភ្នំពេញ និងកាលវិភាគបញ្ចេញសំរាមរបស់ក្រុមហ៊ុនប្រមូលសំរាមនោះ បានរកឃើញថា ទីតាំងលំនៅឋានក្រីក្រមានត្រឹមតែ ១៩ភាគរយ ទាបជាងទីតាំងលំនៅឋានទូទៅដែលមាន ២៨ភាគរយ។ សម្រាប់អ្នកបញ្ចេញខុសម៉ោងកំណត់ទាំងទីតាំងលំនៅឋាក្រីក្រ និងទីតាំងលំនៅឋានទូទៅមានរហូត ៥៣ភាគរយឯណ្ណោះនៃអ្នកផ្តល់បទសម្ភាសសរុប។ លទ្ធផលនេះបង្ហាញថាការបញ្ចេញសំរាម សំណល់រឹងខុសម៉ោងមានភាគរយខ្ពស់បែបនេះ ដោយសារតែភាគច្រើនជាពួកគេមិនទទួលបានកាលវិភាគកំណត់ម៉ោងជាក់លាក់ដើម្បីបញ្ចេញសំរាម និងជាការកង្វះភាពស៊ីចង្វាក់គ្នារវាងអ្នកប្រើប្រាស់សេវាកម្ម និងប្រតិបត្តករផ្តល់សេវាកម្មប្រមូលសំរាមរបស់ក្រុមហ៊ុនប្រមូលសំរាមផងដែរ។ ជាងនេះទៀត ក៏អាចការកង្វះខាតយន្តការតាមដានត្រួតពិនិត្យជាប្រចាំលើសកម្មភាពបញ្ចេញសំរាមរបស់ប្រជាពលរដ្ឋ និងការប្រមូលសំរាមរបស់ក្រុមហ៊ុនប្រមូលសំរាម។ ក្នុងករណីនេះ អាជ្ញាធរមូលដ្ឋានក៏បានលើកឡើងផងដែរថា កាលវិភាគបញ្ចេញសំរាមកន្លងមក គឺបានផ្តល់ជូនតែប្រជាពលរដ្ឋដែលជាប់ផ្លូវធំ ឬផ្លូវជាតិ ហើយសម្រាប់ទីតាំងលំនៅឋានក្រីក្រ គឺតម្រូវឱ្យយកសំរាមមកចោលនៅទីតាំងដែលបានកំណត់ដោយអាជ្ញាធរ។ ដូច្នេះទីតាំងលំនៅឋានក្រីក្រមិនបានដឹងទេថាទីតាំងចោលសំរាមក្នុងខណ្ឌដែលខ្លួនរស់នៅ តម្រូវឱ្យបញ្ចេញសំរាមនៅពេលវេលាកំណត់ណាមួយនោះទេ ហើយអាជ្ញាធរ ឬក្រុមហ៊ុនប្រមូលសំរាមក៏មិនបានចុះមកផ្សព្វផ្សាយដល់មូលដ្ឋានឱ្យគ្រប់ភូមិនោះដែរ កត្តានេះជាហេតុផលមួយដែលបង្កឱ្យមានគំនរសំរាមគ្រប់ពេល និងគ្រប់ទីកន្លែង ហើយអាចធ្វើឱ្យប៉ះពាល់ដល់សោភណ្ឌភាពទីក្រុងផងដែរ។

---

១៥ ដូចខាងលើឯកសារយោងលេខ១៤

១៦ ដូចខាងលើឯកសារយោងលេខ១៤

តារាង ៧ លទ្ធផលផ្ទៀងផ្ទាត់កាលវិភាគប្រមូលសំរាមរបស់ក្រុមហ៊ុនផ្តល់សេវាកម្មប្រមូលសំរាមទាំងបី និង សេចក្តីណែនាំរបស់សាលារាជធានីភ្នំពេញ រវាងម៉ោងបញ្ចេញសំរាមរបស់ទីតាំងលំនៅឋានក្រីក្រ។

| ខណ្ឌគោលដៅ | ចំនួនអ្នកផ្តល់បទសម្ភាស(នាក់) | ការបញ្ចេញសំរាមរបស់ទីតាំងលំនៅឋានក្រីក្រ | |
|---|---|---|---|
| | | ត្រឹមត្រូវតាមម៉ោងកំណត់ | មិនត្រឹមត្រូវតាមម៉ោងកំណត់ |
| ក្រុមហ៊ុនប្រមូលសំរាមស៊ីនទ្រី | | | |
| ១.ចំការមន | ១៦ | ៦ | ១០ |
| ២. ច្បារអំពៅ | ៤៦ | ២២ | ២៤ |
| ៣. មានជ័យ | ៩ | ២ | ៧ |
| ក្រុមហ៊ុនប្រមូលសំរាមមីហ្សូដា | | | |
| ៤. ដង្កោ | ៦ | ២ | ៤ |
| ៥.ពោធិ៍សែនជ័យ | ១៥ | ៤ | ១១ |
| ក្រុមហ៊ុនប្រមូលសំរាម៨០០ Supper/GAEA | | | |
| ៦.ឫស្សីកែវ | ១២ | ៣ | ៩ |
| សរុប | ១០៤ | ៣៩ | ៦៥ |

តារាង ៨ លទ្ធផលផ្ទៀងផ្ទាត់កាលវិភាគប្រមូលសំរាមរបស់ក្រុមហ៊ុនផ្តល់សេវាកម្មប្រមូលសំរាមទាំងបី និង សេចក្តីណែនាំរបស់សាលារាជធានីភ្នំពេញ រវាងម៉ោងបញ្ចេញសំរាមរបស់ទីតាំងលំនៅឋានទូទៅ។

| ខណ្ឌគោលដៅ | ចំនួនអ្នកផ្តល់បទសម្ភាស(នាក់) | ការបញ្ចេញសំរាមរបស់ទីតាំងលំនៅឋានទូទៅ | |
|---|---|---|---|
| | | ត្រឹមត្រូវតាមម៉ោងកំណត់ | មិនត្រឹមត្រូវតាមម៉ោងកំណត់ |
| ក្រុមហ៊ុនប្រមូលសំរាមស៊ីនទ្រី | | | |
| ១.ចំការមន | ១៦ | ១៤ | ២ |
| ២. ច្បារអំពៅ | ៤១ | ២៥ | ១៦ |
| ៣. មានជ័យ | ៩ | ២ | ៧ |
| ក្រុមហ៊ុនប្រមូលសំរាមមីហ្សូដា | | | |
| ៤. ដង្កោ | ៦ | ២ | ៤ |
| ៥.ពោធិ៍សែនជ័យ | ១៥ | ៤ | ១១ |
| ក្រុមហ៊ុនប្រមូលសំរាម៨០០ Supper/GAEA | | | |
| ៦.ឫស្សីកែវ | ១២ | ៩ | ៣ |
| សរុប | ៩៩ | ៥៦ | ៤៣ |

## ៥.៥) ចំណេះដឹងរបស់អ្នកផ្តល់បទសម្ភាសទាក់ទងនឹងច្បាប់ និងបទប្បញ្ញត្តិស្តីអំពីការគ្រប់គ្រងសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ

ទីតាំងលំនៅឋានទូទៅ ដែលបានស្រាវជ្រាវ អ្នកដែលបានយល់ដឹង ឬមានចំណេះដឹងខ្លះៗ ទាក់ទងនឹងសេចក្តីប្រកាស សេចក្តីណែនាំ ឬអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង មានចំនួន ១០៦នាក់ ក្នុងនោះភាគច្រើនជាទីតាំងលំនៅឋានក្រីក្រ ដែលមានចំនួន ៦៦នាក់ និងទីតាំងលំនៅឋានទូទៅចំនួន ៤០នាក់។ ចំណែកអ្នកមិនធ្លាប់បានដឹងមានចំនួន៩៧នាក់ ភាគច្រើនជាប្រជាពលរដ្ឋទីតាំងលំនៅឋានទូទៅមានចំនួន ៥៩នាក់ និងសហគមន៍មានចំនួន៣៨នាក់។ ឆ្នាំ ២០២២ ប្រជាពលរដ្ឋធ្លាប់ទទួលបានកាផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈម្តង ស្តីពីការញែក ការទុកដាក់ និងការបញ្ចេញសំរាម។ អ្នកផ្តល់បទសម្ភាសម្នាក់ប្រាប់ថា៖ មានប្រជាពលរដ្ឋយើងបានលើកឡើងនូវបញ្ហា ហើយបានសំណើសុំឱ្យមានការផ្តល់វគ្គបណ្តុះបណ្តាលអំពីការទុកដាក់សំរាមត្រឹមត្រូវ និងគួរតែមានការចុះត្រួតពិនិត្យ និងវាយតម្លៃលើការទុកដាក់សំរាមជាទៀងទាត់ពីមូលដ្ឋាន ឬក្រុមហ៊ុនប្រមូលសំរាម។

ការសម្ភាសជាមួយអាជ្ញាធរមូលដ្ឋានអំពីការគ្រប់គ្រងសំរាមបានប្រាប់ថា នៅក្នុងមូលដ្ឋានតែងតែរៀបចំប្រជុំធ្វើបច្ចុប្បន្នភាពជារៀងរាល់ខែ ដោយការប្រជុំនេះជាការប្រជុំឆ្លាស់តាមភូមិ។ ការប្រជុំនេះពិភាក្សាពីបញ្ហាស្ថានភាពទូទៅក្នុងភូមិឃុំ និងសម្រាប់បញ្ហាសំរាម សំណល់រឹង ឬសម្អាតបរិស្ថានជារបៀបរៈបន្ទាប់បន្សំ។ សមាជិកចូលរួមប្រជុំមានអាជ្ញាធរមូលដ្ឋានក្នុងតំបន់ និងមិនមានវត្តមានប្រជាពលរដ្ឋនោះទេ។ សម្រាប់ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋគឺរៀបចំជាវេទិកាសាធារណៈប៉ុន្តែការរៀបចំនេះមិនទៀងទាត់ទេ។

ការសម្ភាសជាមួយក្រុមហ៊ុនប្រមូលសំរាមបានប្រាប់ថា ក្រុមហ៊ុនប្រមូលសំរាមបានសហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការរៀបចំផ្សព្វផ្សាយកម្មវិធីសម្អាតក្នុងមូលដ្ឋានមួយខែពីរដង។ ចំពោះការរៀបចំម្តងមានអ្នកចូលរួមចំនួនចន្លោះពី ៤០នាក់ ដល់៨០នាក់ និងមានការផលិតវិដេអូខ្លីទាក់ទងអំពីការណែនាំនានា ហើយបានផ្សព្វផ្សាយក្នុងគេហទំព័រ និងបណ្តាញសង្គម។ គិតដល់ឆ្នាំ២០២៤ ទើបតែចុះផ្សព្វផ្សាយ ១០ភាគរយនៃភូមិជាតំបន់គោលដៅរបស់ខ្លួន។

## ៥.៦) វិភាគការចូលរួមក្នុងកិច្ចការគ្រប់គ្រងសំរាមរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងការឆ្លើយតបរបស់អាជ្ញាធរមូលដ្ឋាន

ទិន្នន័យស្រាវជ្រាវ បានបង្ហាញឱ្យឃើញថាប្រជាពលរដ្ឋទាំងទីតាំងលំនៅឋានក្រីក្រ និងទីតាំងលំនៅឋានទូទៅបានបង្ហាញពីការចូលរួមក្នុងការគ្រប់គ្រងសំរាមក្នុងមូលដ្ឋានរស់នៅរបស់ពួកគេ។ ជាក់ស្តែងអ្នកផ្តល់បទសម្ភាសចំនួន ៧៥នាក់ ប្រាប់ថាមានការកំណត់ទីតាំងឱ្យចោលសំរាម ហើយពួកគេបានចូលរួមអនុវត្តទុកដាក់សំរាមរបស់ពួកគេនៅទីតាំងដែលបានកំណត់នោះមានចំនួន៥៩នាក់ដែលស្មើនឹង៧៩%។ ជាងនេះទៅទៀត បើទោះបីពួកគេត្រឹមតែចំនួន ១០៦នាក់មានចំណេះដឹងបន្តិចបន្តួចទាក់ទងនឹងបទប្បញ្ញត្តិនៃការគ្រប់គ្រងសំរាម សំណល់រឹងក្តី ក៏ឃើញមានចំនួនអ្នកដែលបានអនុវត្តការញែកសំរាម ៦៤នាក់ និងចំនួន៤នាក់បានអនុវត្តការច្រកសំរាមតាមប្រភេទ ពណ៌ដែលបានកំណត់ផងដែរ។ មួយវិញទៀតក្នុងចំណោមអ្នកផ្តល់បទសម្ភាស២០៣នាក់ ចំនួនអ្នកទទួលបានកម្មវិធីបញ្ចេញសំរាម ឬកាលវិភាគបញ្ចេញសំរាមមានតែ៣៣នាក់ប៉ុណ្ណោះ ក្នុងនោះយើងឃើញ

ចំនួនអ្នកចូលរួមបញ្ចេញសំរាមតាមកម្មវិធីបញ្ចេញសំរាមចំនួន២២នាក់។

ដូច្នេះតាមរយៈទិន្នន័យ និងតួលេខខាងលើនេះ បង្ហាញឱ្យឃើញថាប្រជាពលរដ្ឋទាំងទីតាំងលំនៅឋានក្រីក្រ និងទីតាំងលំនៅឋានទូទៅមានឆន្ទៈចូលរួមអនុវត្តស្របតាមបទប្បញ្ញត្តិនានាដែលពួកគេបានទទួលតាមរយៈលទ្ធភាពដែលខ្លួនមាន។ ប៉ុន្តែបើពិនិត្យលើបញ្ហាប្រឈម ពួកគេកំពុងតែជួបបញ្ហា៖

ទី១) ការមិនទទួលបានព័ត៌មានសំខាន់ៗទាក់ទងនឹងម៉ោងបញ្ចេញសំរាមជាក់លាក់ ដែលនេះជាកត្តាប្រឈមដ៏ធ្ងន់ធ្ងរដល់ការបញ្ចេញសំរាមដែលមិនមានពេលវេលាកំណត់ច្បាស់លាស់។ ទិន្នន័យបង្ហាញថាចំនួនបញ្ចេញសំរាមត្រឹមត្រូវតាមម៉ោងកំណត់ គឺក្រោម៥០%។

ទី២) កង្វះការចូលរួម ឬចូលរួមមិនបានពេញលេញក្នុងកិច្ចប្រជុំទាក់ទងការគ្រប់គ្រងសំរាមជាមួយអាជ្ញាធរ និងក្រុមហ៊ុនប្រមូលសំរាម។ កត្តាកង្វះការចូលរួមនេះបណ្តាលឱ្យប្រជាពលរដ្ឋមិនទទួលបានចំណេះដឹងក្នុងការទុកដាក់ ការវេចខ្ចប់ ការញែក និងបញ្ចេញសំរាមនោះ។ ជាងទៀតមានទីតាំងលំនៅឋានទូទៅមានការយល់ច្រលំថាការទុកដាក់សំរាម សំណល់រឹងនៅខាងមុខផ្ទះរបស់ខ្លួនជាទីតាំងមិនបាកំណត់។

ទី៣) យន្តការផ្សព្វផ្សាយពីការណែនាំ អំពីការចូលរួមគ្រប់គ្រងសំរាមមិនទាន់ទូលំទូលាយស្របតាមលក្ខខណ្ឌអ្នកប្រើប្រាស់សេវាកម្ម។ ជាក់ស្តែង ក្រុមហ៊ុនប្រមូលសំរាមបានផលិតវិដេអូខ្លីស្តីពីការគ្រប់គ្រង និងផ្សព្វផ្សាយតាមរយៈគេហទំព័រផ្លូវការរបស់ក្រុមហ៊ុន និងបណ្តាញសង្គមហ្វេសប៊ុកក្តី អ្នកផ្តល់បទសម្ភាសស្ទើរតែទាំងអស់មិនទទួលបាន ឬដឹងពីការផ្សព្វផ្សាយទាំងនោះទេ។

ទី៤) កង្វះយន្តការតាមដាន និងវាយតម្លៃពីអាជ្ញាធរ និងក្រុមហ៊ុនប្រមូលសំរាម។ កត្តានេះអាចធ្វើឱ្យប្រជាពលរដ្ឋមិនដឹងថារកដំណោះស្រាយបែបណា និងពេលដែលប្រាប់បញ្ហាទៅអ្នកពាក់ព័ន្ធតែងតែគ្មានដំណោះស្រាយមកវិញផងដែរ។

# ករណីសិក្សាទី១៖ ការគ្រប់គ្រងសំរាមក្នុងទីតាំងលំនៅឋានក្រីក្រ

## ក. ការចំណាយថវិកាលើសពីថ្លៃសេវា

ដោយផ្លូវចូលទីតាំងលំនៅឋានក្រីក្រមានសភាពតូចចង្អៀត ឬមានទំហំតូចដែលអាចអនុញ្ញាតបានតែម៉ូតូ និងឡានខ្នាតតូចប៉ុណ្ណោះ ចំពោះឡានប្រមូលសំរាម សំណល់រឹងមិនអាចចូលបានទេ ដូច្នេះហើយទើបទីតាំងនេះ មានបញ្ហាកកស្ទះ ឬសំរាម សំណល់រឹងរុំារ៉ៃក្នុងទីតាំងលំនៅឋានក្រីក្រ។ សហមាជិកទីតាំងលំនៅឋានក្រីក្របានស្នើសុំឱ្យមានរទេះពីក្រុមហ៊ុនប្រមូលសំរាមចូលប្រមូលកាលពីដើមឆ្នាំ២០២៣ ក្នុងកិច្ចប្រជុំជាមួយក្រុមហ៊ុន ស៊ីនទ្រី (ខេមបូឌា) និងអាជ្ញាធរមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហាកកស្ទះសំរាម។ ដូចការសន្យាក្រុមហ៊ុនប្រមូលសំរាមបានផ្តល់រទេះតូចតាមការស្នើសុំពិតប្រាកដមែន និងបានផ្តល់ជូនលេខទូរស័ព្ទរបស់ក្រុមហ៊ុន ដើម្បីទុកឱ្យប្រជាពលរដ្ឋរាយការណ៍នៅពេលដែលមាន



*រូបភាពទី៦៖ ទីតាំងលំនៅឋានក្រីក្រមួយមិនទទួលបានសេវាប្រមូលសំរាម*

បញ្ហាឃឺតយ៉ាវមកប្រមូលសំរាម ប៉ុន្តែសកម្មភាពប្រមូលសំរាមតាមរយៈរទេះនេះ ការប្រមូលសំរាម បានតែមួយរយៈពេលខ្លីក៏បាត់ទៅវិញ ហើយលេខទូរស័ព្ទឱ្យសម្រាប់ការឃឺតយ៉ាវក៏ហៅមិនបាន។ សមាជិកម្នាក់និយាយថា "ប្រមូលហ្នឹងបានតែដំបូងៗទេ"។

ដោយមើលឃើញពីបញ្ហាលំបាករបស់ទីតាំងលំនៅឋានក្រីក្រ អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រ (UPWD) បានផ្តល់រទេះតូចល្មម ចំនួន៤ និងមានការចាត់តាំងអ្នកស្ម័គ្រចិត្តចំនួន ៤នាក់ ដើម្បីអនុវត្តការប្រមូលសំរាមក្នុងទីតាំងលំនៅឋានក្រីក្រ ដោយពួកគេទទួលបានប្រាក់ឧបត្ថមចំនួន ៨០ដុល្លារអាមេរិក សម្រាប់អ្នកស្ម័គ្រចិត្តម្នាក់ក្នុង១ខែ ហើយមានរយៈពេល៦ខែ។ រយៈពេល៦ខែកន្លងផុតទៅ ទីតាំងលំនៅឋានក្រីក្រកាន់តែមានស្ថានភាពលំបាកខ្លាំង ព្រោះមិនមានអ្នកស្ម័គ្រចិត្តប្រមូលដោយមិនមានថវិកាឧបត្ថម្ភ ដោយកត្តាជីវភាពទើបពួកគេមិនអាចបន្តធ្វើការងារនេះ។ ក្រោយពីការប្រជុំជជែករកដំណោះដោះស្រាយរវាងសមាជិកពួកគេក៏បានស្នើឱ្យប្រជាសហគមន៍ប្រមូលថវិកាផ្ទាល់ខ្លួនប្រចាំខែ ដើម្បីផ្តល់ឱ្យអ្នកស្ម័គ្រចិត្តទាំងនោះ ប៉ុន្តែមិនមានការយល់ព្រមស្របគ្នា។ ទោះជាយ៉ាងណាអ្នកស្ម័គ្រចិត្តនៅតែបន្តប្រមូលសំរាមពីទីតាំងលំនៅឋានក្រីក្រ ហើយការឧបត្ថម្ភតាមគោលការណ៍ស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋ ដោយការអនុវត្តជាក់ស្តែង ការប្រមូលសំរាមតាមខ្នងផ្ទះនីមួយៗទទួលបាន ១ពាន់រៀល ទៅ ២ពាន់រៀល។



*រូបភាពទី៧៖ ប្រជាពលរដ្ឋត្រូវទុកសំរាមមុខផ្ទះរង់ចាំអ្នកស្ម័គ្រចិត្តប្រមូលសំរាមនៅទីតាំងលំនៅឋានក្រីក្រមកប្រមូលទៅចោល*

ស្ត្រីវ័យ៤០ឆ្នាំម្នាក់ប្រាប់ថា៖

> “បច្ចុប្បន្នបើទោះជាមានអ្នកស្ម័គ្រចិត្តប្រមូលសំរាមក្នុងទីតាំងលំនៅឋានក្រីក្រក្តី នៅតែមានបញ្ហាលំបាក ពេលខ្លះត្រូវសន្សំលុយ មួយពាន់ ឬពីរពាន់មិនហ៊ានចាយទេ ទុកឱ្យអ្នកប្រមូលសំរាម ហើយពេលខ្លះត្រូវដើររកអ្នកប្រមូលសំរាមទាំងនោះប្រាប់ឱ្យមកប្រមូលសំរាមពីផ្ទះរបស់ខ្លួន។”

## ខ. បញ្ហាសំរាមឈានដល់ការប្រើហិង្សាខាងគ្នានឹងគ្នា

ករណីមួយទៀតផ្ទះភាគច្រើនមានទំហំ ៤ម៉ែត្រ គុណនឹង ១៥ម៉ែត្រ និងមិនមានសំយាប់ផ្ទះ ឬទីតាំងទំនេរផ្នែកខាងមុខផ្ទះ ពួកគេតែងតែចោលសំរាមបណ្តោះអាសន្ននៅផ្នែកខាងមុខផ្ទះរបស់ពួកគេជារៀងរាល់ថ្ងៃដោយសារតែទីតាំងចោលសំរាមដែលបានកំណត់ដោយអាជ្ញាធរមានចម្ងាយឆ្ងាយ។ នៅថ្ងៃមួយ ដោយសារតែការទុកដាក់សំរាមមិនបានត្រឹមត្រូវ និងមានក្លិនស្អុយជះដល់ផ្ទះដែលនៅជាប់គ្នាក៏បានបង្កឱ្យមានជម្លោះពាក្យសំដីរហូតឈានដល់ការប្រើអំពើហឹង្សាក្នុងសហគមន៍។

ស្ត្រីវ័យ ៣៨ឆ្នាំម្នាក់ប្រាប់ថា៖

“ខ្ញុំឃើញសំរាមមុខផ្ទះទល់មុខផ្ទះខ្ញុំគរច្រើនថ្ងៃពេក មានក្លិនស្អុយខ្លាំង និងហូរទឹកទៀត ហើយផ្ទះខ្ញុំនៅទល់មុខហ្នឹង ខ្ញុំធ្វើបាយក្តាំងលក់ ពេលខ្លះក៏ត្រូវហាលបាយដែរ។ ពេលឃើញប្តីម្ចាស់ផ្ទះចេញមក (ម្ចាស់ផ្ទះមានសំរាម) ខ្ញុំក៏បានប្រាប់ថាបងអើយសំរាមច្រើនណាស់យកទៅចោលនៅក្រៅទៅ គាត់ក៏ឆ្លើយថាចាំគាត់យកទៅចោលល្ងាចបន្តិច រួចគាត់ក៏ជិះម៉ូតូទៅយកប្រពន្ធចេញពីធ្វើការ ពេលមកដល់ស្រាប់តែប្រពន្ធគាត់ជេស្តីផ្ទះខ្ញុំខ្លាំង ហើយពេលខ្ញុំឆ្លើយតប ប្តីគាត់(ម្ចាស់ផ្ទះមានសំរាម) ក៏មកវាយខ្ញុំហើយប្តីខ្ញុំក៏ចូលជួយ។”

ទំនាស់ដែលកើតចេញពីសំរាមនេះ ឈានទៅដល់ការប្តឹងអាជ្ញាធរមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហានេះ ជាលទ្ធផល ភាគីម្ចាស់ផ្ទះមានសំរាមបានបង់ថ្លៃជំងឺចិត្តចំនួន ២០ម៉ឺនរៀលដល់ភាគីផ្ទះមិនមានសំរាម។



*រូបភាពទី៨៖ ចំហៀងផ្នែកខាងឆ្វេងជាផ្ទះលក់បាយក្តាំង*



*រូបភាពទី៩៖ បាយក្តាំងដែលពួកគេហាលដើម្បីលក់*

## គ. ការយល់ច្រលំថាទីតាំងលំនៅឋានក្រីក្រមិនតម្រូវឱ្យមានការបង់ថ្លៃសេវាប្រមូលសំរាម

ទីតាំងលំនៅឋានក្រីក្រមួយដែលមានសមាជិកស្ទើរទាំងអស់កំពុងយល់ច្រលំថាទីតាំងផ្ទះរបស់ខ្លួនមិនតម្រូវឱ្យបង់ថ្លៃសេវាប្រមូលសំរាមនោះទេ។ នៅពេលអាជ្ញាធររៀបចំវេទិកាសាធារណៈ អញ្ជើញប្រជាពលរដ្ឋចូលរួម ដើម្បីបង្ហាញពីបញ្ហាការមិនបង់ថ្លៃសេវាប្រមូលសំរាម ខណៈពេលនោះ ទីតាំងលំនៅឋានក្រីក្រ បានដឹងថាខ្លួនមានបំណុលសំរាម សំណល់រឹងច្រើន ចន្លោះពីមួយលានរៀល ឬច្រើនជាងនេះ។ ក្នុងឆ្នាំ២០២០ ពួកគេបានស្នើសុំការលុបបំណុល ដោយមូលហេតុពួកគេមិនបានទទួលសេវាកម្មប្រមូលសំរាមទេ ជាលទ្ធផលទីតាំងលំនៅឋានក្រីក្រទទួលបានការលុបបំណុលចោល។

ស្ត្រីវ័យ៤៤ឆ្នាំម្នាក់ប្រាប់ថា៖

> ❝ខ្ញុំមករស់នៅទីតាំងនេះ គឺតែងតែយកទៅដុតក្នុងជីវត្ត ហើយពីរ ឬបីថ្ងៃដុតម្តង តែឥលូវយកចោលក្នុងធុងសំរាមមួយនៅច្រក់ចូលទីតាំងលំនៅឋានក្រីក្រមុខផ្ទះគេទុកចោលហ្នឹង។❞

ករណីនេះ បើទោះមានការលុបបំណុលចន្លោះឆ្នាំ ២០០២ ដល់២០២០ក្តី ទីតាំងលំនៅឋានក្រីក្រក៏មិនបានដឹងថាខ្លួននៅតែមានកាតព្វកិច្ចបង់ថ្លៃសេវាប្រមូលសំរាមបន្តដែរ និងរិតតែមិនបានដឹងថាសាលារាជធានីបានរៀបចំបង្កើតសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រាជធានីភ្នំពេញផងដែរ ហើយការបង់ថ្លៃសេវាសំរាមត្រូវបានបំបែកចេញពីថ្លៃសេវាអគ្គិសនីក៏មិនបានដឹង។ ដូច្នេះទីតាំងលំនៅឋានក្រីក្រហាក់ស្ទើរតែទាំងអស់មិនទទួលបានព័ត៌មាន ឬបានដឹងអំពីបទប្បញ្ញត្តិនានា ឬពីរបៀបបង់ថ្លៃសេវាប្រមូលសំរាមនោះទេ។ បច្ចុប្បន្ន ពួកគេនៅមានបំណុលសំរាមចន្លោះឆ្នាំ ២០២១ ដល់២០២៤នេះ។



*រូបភាពទី១០៖ ផ្លូវចូលទីតាំងលំនៅឋានក្រីក្រមួយកន្លែងដែលឡានដឹកសំរាមចូលប្រមូលមិនបាន*




*រូបភាពទី១១៖ ក្រោយពីមានការលុបចោលបំណុលសំរាមចាស់ឆ្នាំ២០២០ គ្រួសារបានគិតថាទីតាំងខ្លួនមិនបំណុលសំរាមទេ ប៉ុន្តែនៅពេលពិនិត្យក្នុងបង់ថ្លៃសេវាសំរាមអេឡិចត្រូនិច ពួកគេមានបំណុលជាង៣០ម៉ឺនរៀលឯណ្ណោះ។*

ស្ត្រីវ័យចំណាស់ជាអតីតគ្រូបង្រៀនម្នាក់ បានបង្ហាញពីការខកចិត្ត គាត់បាននិយាយថា៖

> ❝ចំពោះការបង់ថ្លៃសេវាភ្លើងគាត់ប្រយ័ត្នប្រយ៉ែងណាស់មិនហ៊ានឱ្យលើសថ្ងៃទេ ព្រោះខ្លាចមានបញ្ហាផ្តាច់ភ្លើង ហើយរឿងសំរាមខ្ញុំដឹងតែគេបញ្ចូលក្នុងថ្លៃភ្លើង ខ្ញុំមិនបានដឹងទាល់តែសោះថាគេបំបែកចេញពីភ្លើងបែបនេះ ហេតុអីមិនផ្សព្វផ្សាយដល់មូលដ្ឋាន ឬភូមិយើងនេះផង ខ្ញុំគ្មានលុយបង់ទេបើបំណុលនេះច្រើនណាស់។❞

សហគមន៍ស្ទើរតែទាំងអស់ មិនបានដឹងពីការបំបែកថ្លៃសេវាប្រមូលសំរាមពីថ្លៃសេវាអគ្គិសនីនោះទេ ជារៀងរាល់ខែពួកគេគិតថាបានបង់ថ្លៃសេវាប្រមូលសំរាមជាមួយសេវាភ្លើងរួចរាល់ហើយ។ តែថ្មីៗនេះ ដើមសប្តាហ៍ខែសីហា មានភ្នាក់ងារចែកវិក័យបត្រភ្លើងមកចែកក្នុងសហគមន៍ បានប្រាប់ឱ្យពួកគាត់បង់ថ្លៃសេវាប្រមូលសំរាមផង ព្រោះពួកគាត់ មានបំណុលថ្លៃសេវាប្រមូលសំរាមទាំងអស់ ហើយការបង់នោះ អាចបង់តាមរយៈភ្នាក់ងារនោះបាន។ សហគមន៍មានការព្រួយបារម្ភខ្លាំងណាស់ ព្រោះពួកគេមានបំណុលចាប់ពី ៤០ម៉ឺនរៀល ឬច្រើនជាងនេះ។

ស្ត្រីវ័យចំណាស់ម្នាក់ប្រាប់ថា៖

"ខ្ញុំភ័យណាស់ មិចបានសុខៗមានបំណុលសំរាមច្រើនចឹង ៤០ម៉ឺនខ្ញុំគ្មានលទ្ធភាពបង់ទេ រាល់ថ្ងៃខ្ញុំមានជំងឺប្រចាំកាយផង មិចមិនប្រាប់ប្រជាពលរដ្ឋឱ្យបានដឹងជាមុនថាមានការបំបែកចេញ។ បើមានការពិន័យមានតែយកផ្ទះខ្ញុំតែម្តងទៅ។"



រូបភាពទី១២៖ ក្រុមហ៊ុនប្រមូលសំរាមស៊ីនទ្រីផ្តល់ជូនធុងសំរាមប្រើប្រាស់ដល់ទីតាំងលំនៅឋានក្រីក្រមួយកន្លែង



រូបភាពទី១៣៖ ស្ត្រីវ័យចំណាស់ច្រើននាក់បង្ហាញអារម្មណ៍សោកស្តាយ ដោយមិនទទួលបានព័ត៌មានស្តីពីការបំបែកសេវាសំរាមពីថ្លៃភ្លើង ហើយមានបំណុលសំរាមដោយមិនដឹងខ្លួន!

# ករណីសិក្សាទី២៖ ការគ្រប់គ្រងសំរាមរបស់ទីតាំងលំនៅឋានទូទៅ

៧៩%នៃទីតាំងលំនៅឋានទូទៅបានយល់ច្រលំថា ទីតាំងផ្នែកខាងមុខផ្ទះរបស់ខ្លួនមិនមែនជាកន្លែងសម្រាប់ទុកដាក់ ឬចោលសំរាមនោះទេ។ ផ្ទុយទៅវិញតាមរយៈការសម្ភាសជាមួយអាជ្ញាធរមូលដ្ឋានបានប្រាប់ថា សម្រាប់ប្រជាពលរដ្ឋដែលនៅផ្នែកខាងមុខអនុញ្ញាតឱ្យចោលសំរាមនៅមុខផ្ទះរងចាំឡានដឹកសំរាមមកប្រមូល និងបានចែកកាលវិភាគប្រមូលសំរាមជូនដល់អ្នករស់នៅផ្លូវធំ។

“ប្រធានភូមិម្នាក់ក្នុងខណ្ឌច្បារអំពៅមានប្រសាសន៍ថា៖ កាលវិភាគប្រមូលសំរាមនេះ គេចែកឱ្យតែអ្នកដែលរស់នៅផ្លូវធំខាងលើប៉ុណ្ណោះ តែសម្រាប់អ្នករស់នៅច្រកតូចៗខាងក្រោមមិនមាននោះទេ។”

“អាជីវករលក់គ្រឿងសំណង់ម្នាក់បានប្រាប់ថា៖ ឡានដឹកសំរាមមកប្រមូលអស់ៗ ប៉ុន្តែមកមិនទៀងទាត់ទេ ជូនមកព្រឹក ជូនមកថ្ងៃ ជូនមកមួយថ្ងៃ២ដងក៏មាន។ សម្រាប់ការទុកដាក់សំរាមរង់ចាំឡានដឹកសំរាមមកប្រមូលរៀងពិបាកបន្តិច ព្រោះខ្លាចមានបញ្ហាលឺមាត់លឺកជាមួយអ្នកជិតខាងណាស់។”

ចំពោះការបង់ថ្លៃសេវាប្រមូលសំរាមវិញ ប្រជាពលរដ្ឋមានការយល់ដឹងច្រើនពីរបៀបនៃការបង់សេវាទាំងនោះ។ អ្នកផ្តល់បទសម្ភាសម្នាក់ប្រាប់ថា៖

“ខ្ញុំតែងតែបង់តាមវីងផ្ទេរប្រាក់ជារៀងរាល់ខែមិនដែលខកខានទេ។”




*រូបភាពទី១៤៖ បុគ្គលិក និងឡានដឹកសំរាមរបស់ក្រុមហ៊ុនស៊ីនទ្រី*

ជាងនេះទៀត ប្រជាពលរដ្ឋផ្តល់បទសម្ភាសម្នាក់រស់នៅផ្លូវធំបានប្រាប់ថា ព័ត៌មានដែលគាត់ទទួលបានតាមរយៈ ទំព័រហ្វេសប៊ុករបស់ក្រុមហ៊ុនប្រមូលសំរាម ដើម្បីទទួលបានព័ត៌មានផ្សេងៗអំពីពីសេវាកម្ម។

# ប្រៀបធៀបករណីសិក្សាលើការប្រើប្រាស់សេវាកម្មប្រមូលសំរាម រវាងទីតាំងលំនៅឋានក្រីក្រ និងទីតាំងទូទៅ

ករណីសិក្សាខាងលើបានបង្ហាញថាទីតាំងលំនៅឋានក្រីក្របានប្រឈមនឹងបញ្ហាធំៗចំនួនបួន៖ ១. ការចំណាយលុយលើសលុបទៅឱ្យបុគ្គលិកស្ម័គ្រចិត្តប្រមូលសំរាមរបស់ពួកគេលើសពីបង់ថ្លៃសេវាកម្មជាមួយក្រុមហ៊ុនប្រមូលសំរាម ២. ការទុកដាក់សំរាមក្នុងទីតាំងលំនៅឋានក្រីក្របង្កឱ្យមានទំនាស់ពាក្យសំដីឈានដល់អំពើហិង្សា ៣. ការមិនទទួលបានការជូនដំណឹងទាក់ទងនឹងការបន្តបង់ថ្លៃសេវាប្រមូលសំរាម និង ៤. ការធ្លាក់ក្នុងបំណុលក្រោយពីការមិនទទួលបានព័ត៌មានពីការផ្តាច់ថ្លៃសេវាប្រមូលសំរាមពីថ្លៃអគ្គិសនី។

បញ្ហាទាំងនេះ ទំនងជាខ្វះការគាំទ្រអន្តរាគមន៍ពីអ្នកពាក់ព័ន្ធសំខាន់ៗដូចជាភាគីអាជ្ញាធរមូលដ្ឋាន និងក្រុមហ៊ុនប្រមូលសំរាម និងយន្តការត្រួតពិនិត្យវាយតម្លៃលើការផ្តល់សេវាកម្ម ឬការទទួលបានសេវាកម្មរបស់អតិថិជនជាទៀងទាត់ដល់ទីតាំងគោលដៅទាំងអស់នោះ។ ជាក់ស្តែងទីតាំងលំនៅឋានក្រីក្រត្រូវតែទទួលបានការដោះស្រាយបន្ទាន់ ព្រោះពួកគេក៏តម្រូវឱ្យបង់ថ្លៃសេវាប្រមូលសំរាមជារៀងរាល់ខែផងដែរ។

ប្រសិនបើប្រៀបធៀបស្ថានភាពទីតាំងលំនៅឋានក្រីក្រ និងទីតាំងលំនៅឋានទូទៅ ឃើញថា ទីតាំងលំនៅឋានទូទៅទទួលបានកាលវិភាគបញ្ចេញសំរាម សំណល់រឹង។ ជាងនេះទៀតពួកគេតែងតែទទួលបានការអញ្ជើញឱ្យចូលរួមការប្រជុំនានា ទាក់ទងការគ្រប់គ្រងសំរាម សំណល់រឹងក្នុងមូលដ្ឋានជាមួយអាជ្ញាធរ និងក្រុមហ៊ុនប្រមូលសំរាម។ ដូច្នេះក្នុងចំនោមអ្នកផ្តល់បទសម្ភាសជាទីតាំងលំនៅឋានទូទៅអាចទទួលបានចំណេះដឹងច្រើនជាងទីតាំងលំនៅឋានក្រីក្រដែលពួកគេបានដឹងថាមានការបង្កើតសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងថ្មី ដោយមានការបំបែកការបង់ថ្លៃសេវាតាមរយៈលេខកូដជាមួយវិក័យប័ត្រភ្លើងតាមរយៈ ទីភ្នាក់ងារវេលុយ ឬប្រព័ន្ធអេឡិចត្រូនិចរបស់ធនាគារ។

លទ្ធផលនៃការប្រៀបធៀបខាងលើបញ្ជាក់ថា ការទទួលបានការផ្តល់សេវាកម្មប្រមូលសំរាមមិនស្មើគ្នា រវាងទីតាំងលំនៅឋានក្រីក្រ និងទីតាំងលំនៅឋានទូទៅ។

# ៦. បញ្ហាប្រឈមក្នុងការគ្រប់គ្រងសំរាមក្នុងតំបន់គោលដៅដែលបានផ្តល់បទសម្ភាស

៦.១) បញ្ហាប្រឈមចម្បងៗដោយកង្វះការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន

កង្វះយន្តការត្រួតពិនិត្យជាទៀងទាត់លើកត្តាសំខាន់ៗ ដូចជាការញែក ការវេចខ្ចប់ ការទុកដាក់សំរាម និងការកំណត់ទីតាំងចោលសំរាមសម្រាប់តំបន់ដែលមានការលំបាកចំពោះទីតាំងទុកដាក់សំរាមប្រចាំថ្ងៃ។ ជាងនេះទៀតមន្ត្រីបច្ចេកទេសផ្នែកបរិស្ថានតាមសង្កាត់មានចំនួនតែពីររូបដែលទទួលបន្ទុកសហការជាមួយក្រុមហ៊ុនប្រមូលសំរាមក៏មិនទាន់បានផ្តល់នូវវគ្គបណ្តុះបណ្តាលស្តីពីការញែក ការវេចខ្ចប់ ការទុកដាក់សំរាមឱ្យបានទូលំលាយ ឬគ្រប់គ្រាន់នៅឡើយដល់ប្រជាពលរដ្ឋមូលដ្ឋាន ហើយក៏មិនមានការផ្សព្វផ្សាយពីបច្ចុប្បន្នភាពស្តីពីការវាយតម្លៃការចូលរួម និងចំណេះដឹងរបស់ប្រជាពលរដ្ឋលើការគ្រប់គ្រងសំរាមដល់សាធារណជនផងដែរ។ ដូច្នេះប្រជាពលរដ្ឋទាំងសហគមន៍ និងមិនមែនសហគមន៍ក្នុងមូលដ្ឋានមានចំនួនតិចតួចណាស់ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលដែលរៀបចំដោយអាជ្ញាធរមូលដ្ឋាន។

៦.២) បញ្ហាប្រឈមចម្បងៗដោយសារការចូលរួមមិនបានពេញលេញរបស់ក្រុមហ៊ុនប្រមូលសំរាម៖

- តាមរយៈការសម្ភាសជាមួយក្រុមហ៊ុនប្រមូលសំរាមមួយក្នុងចំណោមក្រុមហ៊ុនចំនួនបីក្នុងរាជធានីភ្នំពេញ ការ វិភាគក្រុមគោលដៅ ឬអ្នកប្រើប្រាស់សេវាកម្មមិនទាន់បានធ្វើឱ្យគ្រប់ជ្រុងជ្រោយនៅឡើយ បើទោះបីជាការវិភាគនេះដើរតួនាទីសំខាន់ក្នុងការកំណត់បញ្ហាប្រឈមនានារបស់អ្នកប្រើប្រាស់សេវាកម្ម ដែលមានដូចជា គ្មានសមត្ថភាព គ្មានលទ្ធភាពស្វែងរក ឬទទួលព័ត៌មានអំពីកម្មវិធីប្រមូលសំរាមបានតាមរយៈគេហទំព័របណ្តាញសង្គមនានារបស់ក្រុមហ៊ុន។
- ការផ្សព្វផ្សាយរបស់ក្រុមហ៊ុនប្រមូលសំរាមទាក់ទងនឹងកម្មវិធីប្រមូលសំរាម ការទុកដាក់ ការញែក ការវេចខ្ចប់មិនទាន់បានធ្វើទូលំទូលាយនៅឡើយនៅកម្រិតមូលដ្ឋាន។ ជាក់ស្តែង បើទោះបីជាបច្ចុប្បន្ន ក្រុមហ៊ុនបានផលិតជាវីដេអូខ្លី ឬជាសារអប់រំទាក់ទងនឹងកម្មវិធីប្រមូលសំរាម ការបង់ថ្លៃសេវាប្រមូលសំរាម ហើយបានផ្សព្វផ្សាយតាមរយៈគេហទំព័រ ឬបណ្តាញសង្គមរបស់ខ្លួនក្តី ក៏អ្នកផ្តល់បទសម្ភាសស្ទើរតែមិនបានដឹងអំពីព័ត៌មានទាំងនេះទាល់តែសោះ។ បន្ថែមពីនេះទៀត បើទោះបីជា មានកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការចុះផ្សព្វផ្សាយដល់មូលដ្ឋានពីរដងក្នុងមួយខែ ដែលមានអ្នកចូលរួមចន្លោះពី ៤០នាក់ ទៅ ៨០នាក់ក្តី។ ការរៀបចំផ្សព្វផ្សាយពីកម្មវិធីប្រមូលសំរាមនេះ មិនទាន់គ្រប់គ្រាន់បើធៀបនឹងចំនួនប្រជាពលរដ្ឋក្នុងមូលដ្ឋាន។
- ក្រុមហ៊ុនប្រមូលសំរាមទំនងជាកង្វះវិធានការចុះតាមដានការផ្តល់សេវាកម្មរបស់

ក្រុមហ៊ុនតាមតំបន់គោលដៅ។ បច្ចុប្បន្ន ក្រុមហ៊ុនប្រមូលសំរាមបានអនុវត្តវិធីពីរយ៉ាង ក្នុងការតាមដានការផ្តល់សេវាកម្មរបស់ខ្លួន វិធីទីមួយគឺជាវិធីសាស្ត្របែបបុរាណ ដោយមានការបែងចែកប្រធានក្រុមតាមតំបន់គ្រប់គ្រងបុគ្គលិក និងរថយន្តដឹកសំរាម និងវិធីទីពីរការបំពាក់ប្រព័ន្ធជីភីអេស (GPS) តាមរថយន្តដឹកសំរាម ហើយប្រព័ន្ធនេះត្រូវបានគ្រប់គ្រងដោយក្រសួងបរិស្ថាន។ តាមរយៈការស្រាវជ្រាវវិធីទាំងពីរនេះហាក់មិនមានប្រសិទ្ធភាព ដាក់ស្តែងរថយន្តដឹកសំរាមមកប្រមូលសំរាមមិនទៀងទាត់តាមការកំណត់ក្នុងកាលវិភាគបញ្ចេញសំរាមនោះទេ។

- ក្រុមហ៊ុនប្រមូលសំរាមទំនងជាមិនមានវិធានការវាយតម្លៃការប្រើប្រាស់សេវាកម្មរបស់អតិថិជន និងបញ្ហាផ្សេងទេ។ តាមរយៈការស្រាវជ្រាវក៏រកឃើញថា តួលេខខ្ពស់នៃអ្នកមិនទទួលបានកាលវិភាគបញ្ចេញសំរាមមានចំនួន១៧០ ក្នុងចំនោមអ្នកផ្តល់បទសម្ភាស ២០៣នាក់។ ដូច្នេះកង្វះការចូលរួមរបស់ក្រុមហ៊ុន អ្នកប្រើប្រាស់សេវាកម្មក្រុមហ៊ុនប្រមូលសំរាមបានក្លាយជាអ្នកជំពាក់បំណុលសំរាមខណៈពេលពួកគេទទួលបានការផ្តល់សេវាមិនមានតម្លាភាព។

# ៧. សេចក្តីសន្និដ្ឋាន

យោងតាមលទ្ធផលនៃការសិក្សាស្តីពី "ការគ្រប់គ្រងសំរាម សំណល់រឹងនៅភ្នំពេញ៖ ការប្រៀបធៀបរវាងទីតាំងលំនៅឋានក្រីក្រ និងទីតាំងលំនៅឋានទូទៅ" អាចសន្និដ្ឋានបានថា៖

**ទីមួយ៖** ជាងពាក់កណ្តាលនៃប្រជាពលរដ្ឋដែលបានចូលរួមក្នុងដំណើរការស្រាវជ្រាវនេះ អ្នកផ្តល់បទសម្ភាសអាយុចន្លោះពី ២០ ដល់ ៣៥ឆ្នាំ ភាគច្រើនជាសហគមន៍មានការយល់ដឹងទាបអំពីគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង ដែលជារឿយៗទទួលបានព័ត៌មានពីអង្គការមិនមែនរាជរដ្ឋាភិបាលច្រើនជាងពីអាជ្ញាធរមូលដ្ឋាន។ ចំណុចនេះបង្ហាញពីតម្រូវការរបស់ប្រជាពលរដ្ឋលើការអប់រំជាសាធារណៈ និងការចាប់ផ្តើមកសាងសមត្ថភាព ដឹកនាំក្នុងមូលដ្ឋាន ដែលអាជ្ញាធរមូលដ្ឋានដើរតួនាទីសំខាន់បំពេញចំណុចខ្វះខាត ឬផ្តល់ការយល់ដឹងដល់មូលដ្ឋាន។

**ទីពីរ៖** អ្នកផ្តល់បទសម្ភាសក្នុងដំណើរការស្រាវជ្រាវប្រមាណជា ៤០% បានទទួលស្គាល់ថាខ្លួនមិនបានគោរពតាមការណែនាំអំពីទុកដាក់សំរាម សំណល់រឹងឱ្យបានត្រឹមត្រូវ ដោយលើកឡើងពីការយល់ដឹងមានកម្រិតទាប និងការផ្សព្វផ្សាយព័ត៌មានមិនគ្រប់គ្រាន់។ កង្វះចំណេះដឹងនេះ បានជះឥទ្ធិពលអវិជ្ជមាន រួមទាំងការអនុវត្ត ការចោលសំរាមមិនត្រឹមត្រូវ ប៉ះពាល់ដល់សុខភាពសាធារណៈ និងកង្វះប្រសិទ្ធភាពនៃប្រព័ន្ធប្រមូលសំរាម។

**ទីបី៖** កាលវិភាគនៃការប្រមូលសំរាមមិនស៊ីសង្វាក់គ្នាក៏ជាបញ្ហាដែលប៉ះពាល់ដល់ការប្រមូលសំរាមផងដែរ។ អ្នកចូលរួមក្នុងការស្រាវជ្រាវប្រមាណជា ៥៣% មិនបានបង់ថ្លៃសេវាប្រមូលសំរាមដោយសារតែពួកគេយល់ខុសថាថ្លៃសេវាប្រមូលសំរាមរួមបញ្ចូលនៅក្នុងវិក័យបត្រអគ្គិសនី។

**ទីបួន៖** ការសិក្សានេះគូសបញ្ជាក់ពីតួនាទីសំខាន់របស់អាជ្ញាធរមូលដ្ឋាន និងក្រុមហ៊ុនគ្រប់គ្រងសំរាម សំណល់រឹងក្នុងការដោះស្រាយបញ្ហាប្រឈម។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សាក៏បានបង្ហាញពីការចូលរួមសម្របសម្រួលក្នុងកិច្ចការងារគ្រប់គ្រងមានកម្រិត ឬមិនទាន់បានល្អប្រសើរ និងប្រព័ន្ធតាមដានត្រួតពិនិត្យវាយតម្លៃមិនទាន់ត្រូវអនុវត្តបានពេញលេញ។ ខណៈពេលដែលមានការរីកចម្រើនមួយចំនួន រួមទាំងការដាក់ឱ្យប្រើប្រាស់ការតាមដាន GPS សម្រាប់រថយន្តប្រមូលសំរាម និងការប្រជុំសហគមន៍ ការផ្សព្វផ្សាយព័ត៌មាននៅតែមិនទាន់គ្រប់គ្រាន់។ គ្រួសារមួយចំនួនតូចប៉ុណ្ណោះដែលបានទទួលព័ត៌មានអំពីកាលវិភាគ និងការអនុវត្តការចោលសំរាម សំណល់រឹងបានត្រឹមត្រូវ។

ជារួមការប្រើប្រព័ន្ធឌីជីថលគឺជាចំណុចសំខាន់សម្រាប់ការកែលម្អការគ្រប់គ្រងសំរាម សំណល់រឹងដែលអាចជំរុញឱ្យមានការចូលរួមច្រើនពីទីតាំងលំនៅឋានក្រីក្រ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងការដំណោះស្រាយបញ្ហារួមគ្នា។ លើសពីនេះការបង្កើនការប្រាស្រ័យទាក់ទងប្រកបដោយតម្លាភាព ការត្រួតពិនិត្យជាប់លាប់រវាងទីតាំងលំនៅឋានទូទៅ ទីតាំងលំនៅឋានក្រីក្រ អាជ្ញាធរមូលដ្ឋាន និងក្រុមហ៊ុនប្រមូលសំរាម គឺជាយន្តការចាំបាច់ដើម្បីបង្កើតក្របខ័ណ្ឌគ្រប់គ្រងសំរាម សំណល់រឹងប្រកបដោយនិរន្តរភាព និងសមធម៌។

# ៨. អនុសាសន៍សំខាន់ៗ

**យោងតាមលទ្ធផលនៃការសិក្សានេះ ខាងក្រោមជាអនុសាសន៍រួម៖**

**១) ជានាភាពងាយស្រួល និងពង្រីកមធ្យោបាយនានាក្នុងការចាត់ចែង និងគ្រប់គ្រងសំរាម៖**
នៅទីតាំងលំនៅឋានក្រីក្រជាច្រើនមិនមានមធ្យោបាយគ្រប់គ្រាន់សម្រាប់ការចោលសំរាម សំណល់រឹងឡើយ។ ហេតុនេះត្រូវតែមានកិច្ចអន្តរាគមន៍បន្ទាន់ក្នុងការបង្កើតកន្លែងប្រមូលសំរាម ជាពិសេសនៅក្នុងការតាំងទីលំនៅមិនរៀបរយ។ ឧទាហរណ៍ យើងអាចចាប់ផ្តើមគម្រោងតូចៗដើម្បីប្រើឡានដឹកសំរាមតូចៗដែលអាចធ្វើដំណើរតាមផ្លូវតូចៗ និងចង្អៀតបាន។ លើសពីនេះ យើងអាចរៀបចំចំណុចប្រមូលសំរាមបន្តនៅកន្លែងដែលឡានប្រមូលសំរាមពិបាកទៅដល់។ ហើយយើងគួរតែពិនិត្យមើលឱ្យបានទៀងទាត់ថាតើវិធីសាស្ត្រនេះដំណើរការហើយអាចពង្រីកបានដែរឬទេ។ យុទ្ធសាស្ត្រនេះគួរតែត្រូវបានវាយតម្លៃជាទៀងទាត់សម្រាប់ការធ្វើមាត្រដ្ឋានដោយផ្អែកលើប្រសិទ្ធភាពរបស់វា។

**២) គំនិតផ្តួចផ្តើមការបែងចែកសំរាម សំណល់រឹងដែលជំរុញដោយទីតាំងលំនៅឋានក្រីក្រ៖**
ដើម្បីបង្កើនការ ចូលរួមក្នុងការញែកសំរាម សំណល់រឹង កម្មវិធីលើកទឹកចិត្តតាមទីតាំងលំនៅឋានក្រីក្រអាចត្រូវបានចាប់ផ្តើមដើម្បីផ្តល់រង្វាន់ដល់គ្រួសារដែលញែកសំរាម សំណល់រឹងឱ្យបានត្រឹមត្រូវ។ ជាងនេះទៅទៀត សេវាប្រមូលសំរាម សំណល់រឹងត្រូវតែពង្រឹងយ៉ាងច្បាស់នូវសារៈសំខាន់នៃការញែកដោយការប្រមូលសំរាមសំណល់រឹងដែលបានតម្រៀបដោយឡែកពីគ្នា។ ការសង្កត់ធ្ងន់គួរតែត្រូវបានដាក់លើការបង្កើតក្របខ័ណ្ឌត្រួតពិនិត្យដែលអនុញ្ញាតឱ្យទីតាំងលំនៅឋានក្រីក្រជានាការអនុលោមតាមកម្មករប្រមូលសំរាម សំណល់រឹង។

**៣) កាលវិភាគ និងការត្រួតពិនិត្យការប្រមូលសំរាម សំណល់រឹងឌីជីថល៖** ការជានាការប្រមូលសំរាម សំណល់រឹងជាប់លាប់តម្រូវឱ្យមានការរួមបញ្ចូលបច្ចេកវិទ្យាទំនើប។ កម្មវិធីទូរស័ព្ទដែលផ្តល់នូវការអាប់ដេតតាមពេលវេលាជាក់ស្តែងលើកាលវិភាគប្រមូលសំរាម សំណល់រឹង និងអនុញ្ញាតឱ្យអ្នករស់នៅរាយការណ៍ពីការប្រមូលដែលខកខាននឹងធ្វើអោយប្រសើរឡើងយ៉ាងខ្លាំងនូវភាពជឿជាក់នៃសេវាកម្ម។ លើសពីនេះ ប្រព័ន្ធតាមដានគួរតែត្រូវបានអនុវត្ត ដើម្បីឱ្យទីតាំងលំនៅឋានក្រីក្រ និងអាជ្ញាធរមូលដ្ឋានត្រួតពិនិត្យចលនានៃយានយន្តប្រមូលសំរាម សំណល់រឹង ដោយជានាថាពួកគេប្រកាន់ខ្ជាប់នូវកាលវិភាគដែលបានគ្រោងទុក។ ទីតាំងលំនៅឋានក្រីក្រ និងទីតាំងលំនៅឋានទូទៅ។

**៤) ការពង្រឹងភាពជាដៃគូសាធារណៈ និងឯកជនសម្រាប់អភិបាលកិច្ចប្រសើរឡើង៖** ការលើកកម្ពស់អភិបាលកិច្ចសំណល់ទាមទារឱ្យមានកិច្ចសហការកាន់តែខ្លាំងរវាងអាជ្ញាធរសាធារណៈ ក្រុមហ៊ុនគ្រប់គ្រងការប្រមូលសំរាម សំណល់រឹងឯកជន និងទីតាំងលំនៅឋានក្រីក្រដែលពួកគេបម្រើ។ ការប្រជុំសហគមន៍ជាទៀងទាត់គួរតែត្រូវបានរៀបចំជាស្ថាប័ន ដើម្បីអនុញ្ញាតឱ្យប្រជាពលរដ្ឋពិភាក្សាអំពីបញ្ហាប្រឈមនៃការគ្រប់គ្រងសំរាម សំណល់រឹង និងស្នើដំណោះស្រាយ។ ការបណ្តុះបណ្តាលសម្រាប់អ្នកដឹកនាំមូលដ្ឋាន

ក្នុងការសម្របសម្រួល និងការដោះស្រាយបញ្ហានឹងផ្តល់សិទ្ធិអំណាចឱ្យពួកគេសម្របសម្រួលប្រកបដោយប្រសិទ្ធភាពរវាងប្រជាពលរដ្ឋ និងអ្នកផ្តល់សេវាសំរាម សំណល់រឹង។

**៥) ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ៖** វាមានសារៈសំខាន់ណាស់ក្នុងការត្រួតពិនិត្យការអនុវត្តគោលនយោបាយជាតិគ្រប់គ្រងសំរាម សំណល់រឹងនៅថ្នាក់មូលដ្ឋាន។ ការវាយតម្លៃភាគីឯករាជគួរតែត្រូវបានធ្វើឡើងដើម្បីវាយតម្លៃការអនុវត្តរបស់ក្រុមហ៊ុនគ្រប់គ្រងការប្រមូលសំរាម សំណល់រឹង ។ លទ្ធផលនៃការវាយតម្លៃទាំងនេះគួរតែប្រើប្រាស់ និងរួមចំណែកដល់ការកែសម្រួលគោលនយោបាយដើម្បីធានាថាសេវាកម្មកាន់តែប្រសើរឡើង និងជួយលើកតំកើននូវសុខមាភាពប្រជាពលរដ្ឋ និងលើកកម្ពស់សោភណ្ឌភាពទីក្រុង។

លទ្ធផលនៃការសិក្សានេះបង្ហាញពីតម្រូវការបន្ទាន់សម្រាប់ប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងដែលរួមបញ្ចូល និងឆ្លើយតបនៅក្នុងទីក្រុងភ្នំពេញ ដែលជាស្ពានតភ្ជាប់គម្លាតរវាងក្របខ័ណ្ឌគោលនយោបាយ និងការពិតនៃការរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសនៅក្នុងសហគមន៍។ តាមរយៈការអនុវត្តការកែលម្អហេដ្ឋារចនាសម្ព័ន្ធគោលដៅ ការបង្កើនការចូលរួមជាសាធារណៈ និងការទទួលយកបច្ចេកវិទ្យាច្នៃប្រឌិត ទីក្រុងភ្នំពេញអាចដោះស្រាយបញ្ហាប្រឈមសំខាន់ៗនៃការគ្រប់គ្រងសំរាម សំណល់រឹងប្រកបដោយប្រសិទ្ធភាព។ ទីបំផុត ទីក្រុងស្អាតជាង សុខភាពល្អ និងនិរន្តរភាពជាងនេះ គឺអាចទទួលបានតាមរយៈសកម្មភាពសម្របសម្រួល និងការចូលរួមជាបន្តបន្ទាប់ក្នុងចំណោមទីតាំងលំនៅឋានក្រីក្ររដ្ឋាភិបាល និងសេវាកម្មគ្រប់គ្រងសំរាម សំណល់រឹងឯកជន។ ការសិក្សានេះអំពាវនាវឱ្យមានអន្តរាគមន៍ជាបន្ទាន់ដែលផ្តល់អាទិភាពដល់ទីតាំងលំនៅឋានក្រីក្រដែលងាយរងគ្រោះបំផុត និងការពង្រឹងរចនាសម្ព័ន្ធអភិបាលកិច្ច ដើម្បីធានាថាការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងមានសមធម៌ និងនិរន្តរភាពនៅទូទាំងក្រុមសេដ្ឋកិច្ចសង្គមទាំងអស់ក្នុងរាជធានីភ្នំពេញ។

**អនុសាសន៍ជាក់លាក់សម្រាប់ភាគីពាក់ព័ន្ធ**

**ប្រជាពលរដ្ឋមូលដ្ឋានទាំងទីតាំងលំនៅឋានក្រីក្រ និងទីតាំងលំនៅឋានទូទៅ៖**

- ❒ ប្រជាពលរដ្ឋ គួរតែឈ្វេងយល់ពីទំព័រហ្វេសប៊ុករបស់ក្រុមហ៊ុនប្រមូលសំរាម សំណល់រឹង និងសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដើម្បីទទួលបានព័ត៌មានដែលទាក់ទងនឹងការគ្រប់គ្រងសំរាម សំណល់រឹង។
- ❒ ប្រជាពលរដ្ឋទាំងអស់ត្រូវចូលរួមអនុវត្តការវេចខ្ចប់បែងចែកប្រភេទសំរាម សំណល់រឹង ចំពោះសំរាម សំណល់រឹងស្ងួត និងសំរាម សំណល់រឹងសើមឱ្យបានត្រឹមត្រូវ ដើម្បីទទួលបានបរិស្ថានល្អ និងសុខមាលភាពក្នុងក្រុមគ្រួសារ។
- ❒ ចំពោះប្រជាពលរដ្ឋ ដែលមានបំណុលសំរាម សំណល់រឹង គួរតែស្នើសុំការពន្យល់ពីសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរាជធានីភ្នំពេញ។
- ❒ លើកទឹកចិត្តឱ្យប្រជាពលរដ្ឋចូលរួមបង់ថ្លៃសេវាប្រមូលសំរាម សំណល់រឹងជូនសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹង និងតាមដានប្រភេទទីតាំងផ្តល់សេវានិងតម្លៃសេវាកម្ម ដែលបានកំណត់ថ្មីនេះ។

ប្រសិនបើមានចំណុចមិនយល់សូមស្នើសុំការពន្យល់ពីសហគ្រាសភ្លាម។

- ប្រជាពលរដ្ឋភាគច្រើនមានការយល់ច្រលំចំពោះការបង់ថ្លៃសេវាប្រមូលសំរាម សំណល់រឹង និងស្នើសុំឱ្យតម្លៃសេវាកម្មបញ្ចូលក្នុងសេវាអគ្គិសនីតែម្តង ដើម្បីកាត់បន្ថយការយល់ច្រលំរបស់ប្រជាពលរដ្ឋ។

## អាជ្ញាធរមូលដ្ឋាន៖

- អាជ្ញាធរមូលដ្ឋាន ឬសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹង ត្រូវតែជូនដំណឹងប្រចាំខែដល់ប្រជាពលរដ្ឋមិនបានបង់ថ្លៃសេវាទៀងទាត់ ដើម្បីកាត់បន្ថយភាពការបាត់ ឬមិនទទួលព័ត៌មាននានា ស្តីពីការបង់ថ្លៃសេវាសំរាម សំណល់រឹង។
- រដ្ឋបាលសាលារាជធានី ឬសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹង គួរតែផ្តល់វគ្គបណ្តុះបណ្តាលបន្ថែមដល់មន្ត្រីមូលដ្ឋាន ដើម្បីឱ្យការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងក្នុងមានប្រសិទ្ធិភាព។
- អាជ្ញាធរមូលដ្ឋានគួរតែកំណត់ទីតាំង ឬកន្លែងស្តុកសំរាម សំណល់រឹងដែលអាចស្តុកសំរាម សំណល់រឹងបានបរិមាណច្រើន មិនប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ និងការកាកស្ទះចរាចរណ៍។
- អាជ្ញាធរមូលដ្ឋានត្រូវតែរិតបណ្តឹងការអនុវត្តការងារជាមួយគណៈកម្មការទទួលបន្ទុកគ្រប់គ្រងសំរាម សំណល់រឹង លើការតាមដានទីតាំងទុកដាក់សំរាម សំណល់រឹង ដើម្បីបញ្ចៀសជម្លោះរបស់ប្រជាពលរដ្ឋទាក់ទងនឹងបញ្ហាសំរាម សំណល់រឹង។
- បញ្ហាសំរាម សំណល់រឹងគួតតែត្រូវបានបញ្ចូលក្នុងកម្មវិធីអប់រំតាំងពីថ្នាក់បឋមសិក្សា ដើម្បីបណ្តុះស្មារតីមានការចូលរួម។

## ក្រុមហ៊ុនប្រមូលសំរាម សំណល់រឹង៖

- ក្រុមហ៊ុនគួរតែបន្ថែមធុងសំរាម សំណល់រឹងដែលមានការបែងចែកធុងសំរាម សំណល់រឹងតាមពណ៌ និងប្រភេទសំរាម សំណល់រឹងនៅតាមទីតាំងដែលបានកំណត់ឱ្យចោលសំរាម សំណល់រឹងដោយអាជ្ញាធរមូលដ្ឋាន។
- ក្រុមហ៊ុនប្រមូលសំរាម សំណល់រឹងត្រូវតែបន្ថែមបុគ្គលិកលាងសម្អាតដេប៉ូសំរាម សំណល់រឹងជាប្រចាំ ដើម្បីបំបាត់ក្លិនស្អុយ និងទទួលបានសោភណ្ឌភាពស្អាត និងអនាម័យ។
- ក្រុមហ៊ុនប្រមូលសំរាម សំណល់រឹងត្រូវបន្តផ្សព្វផ្សាយដល់មូលដ្ឋាន នៅតាមភូមិដែលមិនទាន់បានផ្សាយ ដើម្បីធានាថាប្រជាពលរដ្ឋទទួលបានព័ត៌មានស្មើៗគ្នា និងមិនមានការយល់ច្រលំនានា។
- ក្រុមហ៊ុនប្រមូលសំរាម សំណល់រឹងត្រូវតែចែកកម្មវិធី ឬកាលវិភាគប្រមូលសំរាម សំណល់រឹងដល់ប្រជាពលរដ្ឋឱ្យគ្រប់ខ្នងផ្ទះក្នុងតំបន់ដែលខ្លួនទទួលផ្តល់សេវាកម្មប្រមូលសំរាម សំណល់រឹង ដើម្បីធានាភាពស៊ីចង្វាក់ចំពោះម៉ោងបញ្ចេញ និងម៉ោងប្រមូលសំរាម សំណល់រឹង។



(+855) 023 431 555

sttcambodia

https://teangtnaut.org/